សៀវភៅសិក្សា

ហ៊ុន-គឹមសៀ

# មូលដ្ឋាន

# ដើម្បីយល់អក្សរសាស្ត្រ

សម្រាប់ថ្នាក់ទី ៤-៣-២-១

វវ.15

[illegible]ម សិក្សាទំនើប

៤៩៥.
៩៣២
ហ៊ុន

[illegible] ភ្នំពេញ លេខ ៥៩ ឧថីថាំស្ទ៊ុរ

ភ្នំពេញ

895.932 ហ៊ុន

# សៀវភៅសិក្សា

ហ៊ុន - គឹមសៀ

## មូលដ្ឋាន

# ដើម្បីយល់អក្សរសាស្ត្រ

ជាជំនួយដល់ការពិចារណា...

## សម្រាប់ថ្នាក់ទី ៤-៣-២-១

ការផ្សាយរបស់
បណ្ណាគារភ្នំពេញ
លេខ ៥៩ វិថីបាស្ទ័រ ភ្នំពេញ

ព.ស. ២៥០៦ — គ.ស. ១៩៦៣

(បណ្ណាគារភ្នំពេញ រក្សាសិទ្ធិ)

# អារម្ភកថា

មានមិត្រសំឡាញ់ក៏ដូចជាសិស្សានុសិស្សភាគច្រើនបានថ្លែងសួរយើងខ្ញុំថា: "ក្នុងការរៀនអក្សរសាស្ត្រមានជួបប្រទះនឹងការលំបាកច្រើន បែបគោកក្រទាំងនាំឲ្យធុញហើយរៀនមិនសូវចូល..." ។

និយាយរួម តាមការពិនិត្យរបស់យើងខ្ញុំក៏យល់ឃើញបាននូវសភាពនឹងលក្ខណៈបែបខាងលើនេះមែនអីចឹងដែរ ពីព្រោះយើងមិនទាន់ធ្លាប់.. ប៉ុន្តែយើងខ្ញុំសុំមានយោបល់ដូចតទៅនេះ៖

ហេតុអ្វីបានជារៀនមុខវិជ្ជាអក្សរសាស្ត្រក៏ចេះតែបែបគោកក្រទាំង... តើមុខវិជ្ជានេះក៏គោកក្រទាំងដូចជាយើងបានប្រទះមែនឬទេ ?

បុរាណនិយាយថា "ទម្លាប់យូរទៅៗជាធ្លាប់ ធ្លាប់យូរទៅៗជាធម្មជាតិ (ធម្មតា)" ។ ពិតមែនណាស់ ការក្រចំពោះអ្នកធ្លាប់ទៅជាងាយ ការសម្លាយចំពោះអ្នកមិនធ្លាប់ទៅជាលំបាក ។ មុខវិជ្ជាអក្សរសាស្ត្រក៏ជាមុខវិជ្ជាមួយ ដូចគ្នានឹងមុខវិជ្ជាដទៃទៀត

ដែលយើងពល់គ្នាធ្លាប់បានរៀនកន្លងមកអំពីងដែរ ហើយមុខវិជ្ជានេះ ក៏វិវត្តិជឿនលឿនទៅតាមសន្ទុះនៃអត្ថភាពសង្គម (Existence sociale) មនុស្សថែមទៅទៀតផង (ខនេះគុសបញ្ជាក់ឲ្យឃើញថា អក្សរសាស្ត្រក៏មានបរិតដូចគ្នានឹងមុខវិជ្ជាដទៃ ) ហេតុនេះ រូបយើងនិមួយៗ ដែលជាសមាសភាព ជាធម្មតាយើងក៏គួរតែបានយល់ បានចេះដឹងនូវមុខវិជ្ជានេះជាចាំបាច់ ទោះតិចឬច្រើននិយាយរួម ៗ

ក្នុងការសិក្សាលើកដំបូងដោយប្រៀបធៀប ទោះបីយ៉ាងណាក៏ដោយយើងក៏ត្រូវតែជួបប្រទះនឹងការលំបាក . . . ដូចជាមានពាក្យថ្មី អត្ថន័យទូលាយមានការស៊ីជម្រៅស្រាវជ្រាវរកឫសគល់ ដើម្បីយើងឡើងទៅដល់ចុងបាន ទោះបីជា មុខវិជ្ជាណាក៏ដោយ នេះយើងមិនទាន់និយាយដល់មុខជំនាញនឹងសិល្បៈលាតត្រដាងក្នុងការពន្យល់ប្លែក ៗ គ្នា នៃអ្នកបង្រៀនថែមទៀតផង ៗ

ឧបមាដូចជាយើងចាប់ផ្ដើមរៀនអក្សរ មុនដំបូងយើងក៏ត្រូវតែរៀនតួព្យញ្ជនៈឲ្យចាំស្ទាត់ .. ស្រៈ... ប្រកបអីចឹងដែរ ដល់កាលណាយើងចេះពាក្យមួយចំនួនជាចាំបាច់ហើយទើបយើងអាចអានសៀវភៅបាន យល់អត្ថរសបាន បាត់គោកក្រទាំង បាត់ឃើញអក្សរថែបដូចព្រៃឈើបាត់ធុញទ្រាន់ហើយត្រឡប់ទៅជាចូលចិត្តវិញ...។ ហេតុនេះ ខាងការរៀនអក្សរសាស្ត្រក៏ដូច្នោះដែរ គឺថាមុនដំបូងយើងក៏ត្រូវតែយល់ឲ្យបានច្បាស់នូវវិធាន (loi) នៃអក្សរសាស្ត្រ បន្ទាប់មកយើងត្រូវសិក្សាស្រាវជ្រាវខឿនអក្សរសាស្ត្រជាតិ អន្តរជាតិ (ឲ្យបានបីប្អូនយ៉ាងតិចដើម្បីប្រៀបធៀប) តាមសម័យ តាមកាលៈទេសៈនិមួយៗ ដើម្បីឲ្យយល់នូវព្រឹត្តិការណ៍ផ្សេងៗ ប្រែប្រួលនៅក្នុងសង្គមបន្ទាប់ពីសម័យនិមួយៗ មានវិបត្តនយោបាយសេដ្ឋកិច្ច វប្បធម៌ការចលាចល ការធ្លាក់ចុះអន់ថយ ឬការរុងរឿងជឿនលឿនជាដើម...។

និយាយសង្ខេបទៅគឺថា : កាលណាយើងយល់បានច្បាស់នូវវិធានដែលជាមូលដ្ឋាននៃអក្សរសាស្ត្រហើយ យើងក៏អាចយល់បាននូវបាតុភូតនៃអក្សរសាស្ត្រ យើងក៏អាចរកឃើញនូវមូលហេតុដែលជាកត្តានៃការវិវត្តន៍ ឬវិបត្តិមួយតាមវិស័យអក្សរសាស្ត្រ . . . បន្ទាប់មកទើបយើងនិយាយដល់ការស្ទាត់ជំនាញប៉ិនប្រសប់បាត់ធុញទ្រាន់ ដូចកាលយើងទើបចាប់ផ្ដើមសិក្សា ។

ការសិក្សាអក្សរសាស្ត្រ វាអាចបំភ្លឺឲ្យយើងឃើញបាននូវប្រព័ន្ធអក្សរសាស្ត្រ (Système littéraire) មួយដែលមានមូលដ្ឋានធរមានទៅកន្លែលក្ខណៈមួយ ហើយវាវិវត្តន៍តាមកាលៈទេសៈមួយព្រមទាំងអនុលោមទៅតាមករណីយ៍ជាក់ស្ដែង នៃសង្គមរបស់ប្រទេសនិមួយ ៗ . . . ។ល។

វិជ្ជាអក្សរសាស្ត្រអាចជួយយើងឲ្យមើលឃើញការល្បួងលាស់កែប៉ះទៃនមូការអត្ថាយអាប់អោនដល់កំរិតណាមួយ ដែលសង្គមមនុស្សបានជួបប្រទះក្នុងអតីតកាល ទុកជាមេរៀនកែផ្លូវល្អ

ទៅអនាគត ដែលជាលទ្ធផលនៃបច្ចុប្បន្នដែលយើងត្រូវតែដោះស្រាយក្នុងការអនុវត្តន៍ ។

ក្នុងសៀវភៅនេះ យើងមានលាតត្រដាងនូវរឿងអក្សរសាស្ត្រនៃជាតិដទៃខ្លះទុកជាមូលដ្ឋានខាងគំនិតក្នុងការស្រាវជ្រាវស៊ីជម្រៅនឹងប្រៀបធៀប ដើម្បីវាយតម្លៃអក្សរសាស្ត្រ ឬ ខឿនវប្បធម៌ និយាយរួមនៃជាតិនីមួយៗ...។ ពីព្រោះថា "គេមិនអាចជឿបានថាមហាសាគរវាធំប៉ុន្មានទេ ក្នុងពេលដែលគេមិនទាន់បានឃើញ ឬ បានដឹងអំពីទន្លេ" ។

យើងសុំសរសើរលោកនាយក វិទ្យាល័យ ភិមានអាកាស, ដោយលោកខំប្រឹងយកចិត្តទុកដាក់ជួយយោបល់ដល់យើងក្នុងវិស័យនេះ, ក៏ដូចជាសហប្រតិបត្តិការរបស់លោកជាច្រើនទៀតក្នុងការជួយស្រាវជ្រាវរកមូលដ្ឋានអក្សរសាស្ត្រ នៃ ជាតិនីមួយៗដែរ ។

ថ្ងៃ ១៥-៣-៦៣

ឃ៊ុន - គឹមសៀ

អ្នកបង្រៀនអក្សរសាស្ត្រ នៅវិទ្យាល័យភិមានអាកាស

# អ្វីដែលហៅថាភាសា?

ភាសា គឺជាពាក្យសំដីដែលមនុស្សនិយាយជាសំឡេងចេញមកក្រៅ ឬថាភាសា គឺជាឧបករណ៍១យ៉ាងដែលមនុស្សសម្រាប់ប្រើជាមធ្យោបាយដើម្បីលាតត្រដាងនូវមនោសញ្ចេតនា, គំនិត, សតិអារម្មណ៍ . . . ក្នុងការទាក់ទងរកគ្នា ឲ្យយល់គ្នាបានទៅវិញទៅមកដោយសំដី (ភាសា) ។ និយាយមួយបែបទៀតថា: ភាសាគឺជាបាតុភូត (phénomène) នៃសង្គមមនុស្ស ភាសាវាកើតឡើងអំពីសេចក្ដីត្រូវការរបស់មនុស្សរស់នៅក្នុងសង្គមខាងការបង្ហាញសតិអារម្មណ៍ គំនិតស្មារតី... ឲ្យគ្នាទៅវិញទៅមកក្នុងដំណើរចលនាធ្វើពលកម្ម ដើម្បីរកជីវិត ។ បើគ្មានភាសា មនុស្សមិនអាចមានផលិតផល គ្មានការវិវត្តន៍ជឿនលឿន . . . និយាយរួមទៅ គឺថាវាគ្មានទាំងសង្គមមនុស្សថែមទៅទៀតផង ។

ទាក់ទងយ៉ាងជិតស្និទ្ធនឹងសតិអារម្មណ៍ (គំនិត) ភាសាបានកត់សំគាល់ចំណាំក្នុងពាក្យសំដីនូវបណ្ដាលទ្ធផល នៃការចលនាខាងស្មារតី ខាងការចំរើនជឿនលឿនរបស់មនុស្សក្នុង

ឲ្យយល់បាននូវជឿនការវប្បធម៌ របស់ជាតិយើង និងជាតិនានា ដែលមានទាក់ទងដល់គ្នា ក៏មានសារៈសំខាន់ណាស់ ។

ក្នុងការស្រាវជ្រាវមូលដ្ឋាននៃអក្សរសាស្ត្រ ឬ វប្បធម៌ជាតិ និយាយរួម ក្នុងការស៊ើបជ្រៅឲ្យយល់បានច្បាស់ហើយត្រឹមត្រូវ ផងនូវតម្លៃនិងខ្លឹមសារនៃអក្សរសាស្ត្រជាតិ ក្នុងការណែនាំ ទស្សន៍របស់ខ្លួនឲ្យមានសុភនិច្ឆ័យ មានគំនិតត្រឹមត្រូវ ជាសត្យា-នុមត ( objectif ) ប្រកបដោយគតិបណ្ឌិតខាងការវាយតម្លៃអក្សរសាស្ត្រ ឬ វប្បធម៌ជាតិយើង យើងម្នាក់ៗគប្បីយល់ឲ្យបាននូវជឿនអក្សរសាស្ត្រ ឬ វប្បធម៌នៃជាតិដទៃពីរឬបីថែមទៀត ក្រៅពីជាតិយើងដើម្បីជាកសិណក្នុងការប្រៀបធៀប ។

ពីព្រោះហេតុអ្វី បានជាយើងចង់យល់ឲ្យបានច្បាស់នូវជឿនអក្សរសាស្ត្ររបស់ជាតិយើង ហើយត្រូវឲ្យជាគ្រូវឲ្យដឹងអក្សរសាស្ត្រ ឬ វប្បធម៌ជាតិដទៃផង ? ពីព្រោះថា : ក្នុងការស៊ើបជ្រៅ ការយល់ ការដឹងឲ្យបានច្បាស់លាស់ ហើយត្រឹមត្រូវផង

នូវខឿនការ្យធម៌ នូវខឿនអក្សរសាស្ត្រនិយាយដោយឡែក យើងចង់វាយតម្លៃវាឲ្យត្រូវសមល្មម (កុំឲ្យទាបពេក កុំឲ្យខ្ពស់ពេក) យើងត្រូវការធ្វើការប្រៀបធៀប ។

មានយោបល់ខ្លះឆ្លើយថា : «ទៅចាំបាច់ ប្រៀបធៀបនឹងអក្សរសាស្ត្រ ឬវប្បធម៌ជាតិដទៃធ្វើអី។ ប្រៀបធៀបតែជាមួយនឹងជាតិយើងទៅបានហើយ គឺថាអក្សរសាស្ត្រណាល្អត្រឹមត្រូវគឺវាបំរើជាតិនោះ វាដើរស្របនឹងបំណងជាតិនោះ។...» ។

យើងមានយោបល់ឆ្លើយថា: ការប្រៀបធៀបតាមយោបល់ខាងលើនេះក៏វាសមហើយ គឺថា : អក្សរសាស្ត្ររបស់ជាតិណាមួយវាតាំងតែបំរើផលប្រយោជន៍ជាតិនោះ ទោះក្នុងវិស័យណាក៏ដោយ ទោះតិចឬច្រើន...។ ប៉ុន្តែបើយើងសួរថា: អក្សរសាស្ត្រជាតិនោះវាបំរើផលប្រយោជន៍របស់ជាតិនោះបានដល់កំរិតណាឬតម្លៃអត្ថរសនិងរូបភាព តម្លៃសតិស្មារតីក្នុងកាលៈទេសៈមួយដ៏ជាក់លាក់ តើវាបានដល់កំពស់ណាដែរ ? បើឆ្លើយអំពីកំរិត,

កំពស់, បរិមាណ ... នៃការបំរើរបស់អក្សរសាស្ត្រចំពោះផលប្រយោជន៍ជាតិយើងត្រូវការ ធ្វើការប្រៀបធៀបរវាងអក្សរ-សាស្ត្រជាតិមួយទៅនឹងជាតិមួយទៀតជាដាច់ខាត ។

ឧទាហរណ៍– បើសិនជានៅលើលោកទាំងមូលមានតែមនុស្សម្នាក់ តើមនុស្សនោះអាចដឹងបានថាខ្លួនគាត់ជាអ្វីឬទេ? តើគាត់អាចដឹងថារូបគាត់នេះជាភេទប្រុសឬស្រីទេ? តើគាត់មានឈ្មោះសម្រាប់ហៅឬទេ? តើគាត់ដឹងថាគាត់ជាជាតិអ្វីទេ?... ។ល។ ទេ។ ប្រហែលជាគ្មានបាតុភូតបែបនេះផង បើយើងនិយាយឲ្យរួចបាត់ទៅ ។ និយាយមួយបែបទៀតថា: មនុស្សដឹងបានថាមានភេទប្រុសមកអំពីមានភេទស្រី, ដឹងថាខ្លួនមានទ្រព្យមកអំពីមានអ្នកក្រទ្រព្យ ដឹងថាអក្សរសាស្ត្ររបស់យើងរឹងប៉ឹងមកអំពីមានអក្សរសាស្ត្រជាតិដទៃរាងទន់ខ្សោយ... ។ល។

មុននឹងនិយាយអំពីអក្សរសាស្ត្រ យើងទាំងអស់គ្នាគួរបានយល់ អំពីបញ្ហាភាសាសាស្ត្រជាមុនសិន ពីព្រោះថាបញ្ហាទាំង

ពីនេះវាទាក់ទងគ្នាយ៉ាងជិតជិតណាស់ និយាយមួយបែបទៀតថា: ភាសាសាស្ត្រនិងអក្សរសាស្ត្រវាជាវត្ថុភ្លោះ ។ អក្សរសាស្ត្រគឺគេយកអក្សរជាសញ្ញាសំគាល់ ចំណែកឯភាសាសាស្ត្រវិញគឺគេយកសំឡេងជាសញ្ញាសំគាល់ ហើយម្យ៉ាងទៀត អក្សរសាស្ត្រវាចាប់ផ្ដើមមានរូបរាងចេញមកអំពីភាសា ពីព្រោះហេតុនេះហើយបានជាយើងត្រូវតែដឹងភាសាសាស្ត្រជាមុន ។

# អ្វីគឺជាអក្សរសាស្ត្រ?

សម័យនេះ ស្មារតីសិក្សា ឬ ជាព្យាករណ៍រៀនសូត្រអក្សរសាស្ត្រជាតិ ដោយប្រៀបធៀបទៅគឺមានសន្ទុះលឿនទៅមុខយ៉ាងខ្លាំង មិនថាឡើយ តែចំពោះសិក្ខាកាមដែលជាអ្នកមានករណីយកិច្ចត្រូវតែសិក្សារៀនសូត្រទៅតាមសាលានានា, សូម្បីតែមហាជនសាមញ្ញនៅតាមជនបទចុងកាត់មាត់ញក និយាយរួម... ក៏មានបំណងនឹងគំនិតនឹកឃើញការរៀនសូត្រ, ចេះជឿនជល់ព្រមទាំងត្រូវការចង់ចេះដឹងដែរ, នេះយើងមិនទាន់និយាយដល់អំពីសំណាក់អស់លោកអ្នក សាស្ត្រាចារ្យ បណ្ឌិតបង្រៀនដ៏ច្រើនដែលសុំគឺយកចិត្តទុកដាក់ជជែកវែកញែកគ្នា ដេញដោលរកឫសគល់ទុកជាកសិណ ស្រាវជ្រាវរកឯកសារផ្សេងៗ ដែលជាកស្តុតាងសម្ភារៈនៅកប់សម្ងំក្នុងសារមន្ទីរនានា មានវត្ថុកាកម សិលាចារឹក ប្រាសាទពីបុរាណដែលនៅកប់ក្នុងព្រៃឬលើក្នុងទីជនបទនោះៗ ថែមទៀតផង... ។ល។ ហេតុដូច្នេះយើងអាចសន្និដ្ឋានបានថា: នាទីអក្សរសាស្ត្រក្នុងសម័យបច្ចុប្បន្ន ខាងការស៊ីជម្រៅ

វិស័យត្រិះរិះនឹងការពិចារណា ។ បើគ្មានភាសា សតិអារម្មណ៍របស់មនុស្សមិនអាចឥតមាន (Exister) នឹងកើតចំរើនរហូតមកដល់សព្វថ្ងៃនេះបានឡើយ ។

តាមអត្ថរូបនឹងអត្ថន័យរបស់ភាសាក៏គ្មានចរិតវណ្ណៈឬជាវិសេសឡើងជាន់ថ្នាក់ (Distinction) មនុស្សទេ ភាសាក៏បំរើមនុស្សទាំងមូលដែលមានរស់នៅក្នុងសង្គម ពីព្រោះភាសាក៏ជាមរតកនៃមនុស្សទាំងអស់គ្នា ភាសាក៏ជាមធ្យោបាយរបស់មនុស្សក្នុងការទាក់ទងគ្នាមិនថាវណ្ណៈណា ឬមនុស្សក្នុងជាន់ថ្នាក់ណាទេ ។ ប៉ុន្តែផ្ទុយទៅវិញ មនុស្សដែលរស់នៅក្នុងវណ្ណៈខុសគ្នាត្រឡប់ជាយកចិត្តទុកដាក់ដល់ភាសា សំគីពិចារណានឹងត្រិះរិះចំពោះភាសា ហើយខំប្រឹងកែខៃយកភាសាដែលជាមរតករួមរបស់មនុស្សនោះ ទៅបំរើផលប្រយោជន៍របស់វណ្ណៈរៀងៗខ្លួនទៅវិញ ..ហេតុនេះហើយបានជាគេឃើញមានកើតជាពាក្យខុសៗគ្នាតាមតំបន់ មានទំនៀមទម្លាប់ពាក្យនិងពាក្យផ្សេងៗតាមពួកតាមក្រុមដោយច្បាស់លាស់ ។

យើងទាំងអស់គ្នាបានឃើញនឹងបានយល់ ហើយនូវបញ្ហាភាសាខាងអត្ថន័យ នឹងអក្ខរូបព្រមទាំងគុណប្រយោជន៍របស់វា ចុះចំណែកឯអក្សរសាស្ត្រវិញ តើវាមានអត្ថរសនឹង នាទីផ្ទុកខុសគ្នាយ៉ាងណាទៅដែរ . . . ?

ការពិតភាសានឹងអក្សរវាមិនខុសគ្នាប៉ុន្មានទេ ខាងមូលដ្ឋាន : ដូចយើងបានអធិប្បាយមកខាងលើស្រាប់ហើយថា : ភាសាគេយកសំឡេងនិយាយជាសញ្ញា ចំណែកឯអក្សរវិញគេយកគំនូសជាសញ្ញា ហេតុនេះវាមានការខុសគ្នាបន្តិចតែត្រង់រូបភាព ហើយនឹងគុណធម៌ខ្លះៗ ដូចជាការរក្សាពាក្យសំដីឲ្យបានយូរអង្វែងមិនក្លាយពីសតវត្សរ៍មួយទៅសតវត្សរ៍មួយទៀត ដោយមិនចាប់ត្រូវការមនុស្សជួបគ្នាផ្ទាល់បាន ... ?

អត្ថន័យ— ពាក្យថាអក្សរសាស្ត្រនេះ វាមានន័យបម្រុះយ៉ាងទូលំទូលាយមានបរិតទូទៅ ហើយគំនិតណែនាំអក្សរសាស្ត្រឲ្យស្របទៅតាមទីដៅក៏មានការខុសគ្នាទៅតាមនិន្នាការរបស់អ្នក

ដឹកនាំដែលមានសេចក្ដីប្រាថ្នាជាគោលបំណងខុសៗ គ្នាថែមទៅទៀត ។

គំនិតអ្នកខ្លះ ណែនាំអក្សរសាស្ត្រធ្ងន់ទៅខាងសិល្បៈពេក អ្នកខ្លះធ្ងន់ទៅខាងចរិយាពេក អ្នកខ្លះទៀតធ្ងន់ទៅខាងនយោបាយពេក.. ហេតុនេះហើយបានជាគេឃើញអក្សរសាស្ត្រក្នុងពេលនេះប្រែក្លាយខ្លួនទៅជាឧបករណ៍មួយ សម្រាប់ឃោសនាចលនាមហាជនឲ្យធ្វើការអ្វីមួយតាមយោបល់របស់ខ្លួន ដែលគិតឃើញ... ដូច្នេះយើងអាចសន្និដ្ឋានបានថា: អក្សរសាស្ត្រក៏ជាសភាវៈគ្មានស្មារតី ប៉ុន្តែក៏មានរូបភាពពណ៌សម្បុរអនុលោមទៅតាមឧត្តមគតិ តាមទិន្នាការនៃមនុស្ស ដែលជាអ្នកណែនាំក៏... ប៉ុន្តែនិយាយរួមទៅ យើងអាចឲ្យន័យអក្សរសាស្ត្របានដូចតទៅនេះ ៖

អក្សរសាស្ត្រគឺជាក្បួនខ្នាតឬជាវិជ្ជាមួយ សិក្សាអំពីរបៀបនិងវិធីបង្ហាញមតិអារម្មណ៍ លាតត្រដាងមនោសញ្ចេតនា (ធម្មា

ផ្ទិផ្ទានគំនិតដោយសមត្ថភាពសិល្បៈ) និងការត្រិះរិះរកមធ្យោបាយលាតត្រដាងតាំងនោះ ... ។ល។

អក្សរសាស្ត្រ មានសមត្ថភាព ផ្សាយបន្តនូវ មនោសញ្ចេតនា បណ្ដុះគំនិត បង្កើតការអប់រំឲ្យដល់មនុស្សនានាខាងស្មារតីក៏ដូចជាអាជ្ញាស្រ័យ ...។ អក្សរសាស្ត្រមានបរិតស់អិតសំអាងនិងជ្រើសរើសបណ្ដាវណ្ណកម្មពីអតីតកាល ដែលជាស្នាដៃរបស់មនុស្ស ហើយលាបប្រេងផាត់ម្សៅតាមដំណើររឿងថ្មីនៃកាលៈទេសៈ ដែលជាផលវិភាគនៃការជឿនលឿនរបស់មនុស្សខាងផ្នែកសតិអារម្មណ៍និងស្មារតីក្នុងសម័យនិមួយៗដ៏ជាក់លាក់ ... ។ល។

អក្សរសាស្ត្រមាននាទីបូកសារុបនូវបណ្ដាបាតុភូតរបស់សង្គមមនុស្ស នូវកំរិតជឿនលឿន ឬ សភាពអន់ថយរបស់សង្គមមនុស្សក្នុងកាលៈទេសៈនិងក្នុងសម័យនិមួយៗ ... ។

អក្សរសាស្ត្រមិនមែនគ្រាន់តែជាសមាសភាពសម្ភារៈសម្រាប់

គត់ត្រាសំគាល់នៅក្នុងក្បួនខ្នាត, ច្បាប់ទម្លាប់ ប្រពៃណី គម្ពីរ សាស្ត្រា រឿងក៏វេផ្សេងៗ ប៉ុណ្ណោះទេ... សូម្បីតែបណ្ដារឿងហេតុផ្សេងៗ ដែលមានតែនៅក្នុងពាក្យសំដីនិយាយតៗគ្នា ពីមាត់មួយទៅមាត់មួយនៃមហាជន យើងក៏គួរបានយកចិត្តទុកដាក់ពិចារណាត្រិះរិះសំរិតតាមដានឲ្យណាស់ដែរ ពីព្រោះឥទ្ធិពលនៃរឿងទាំងនោះវាមានសមត្ថភាពអូសទាញនឹងស៊ុជម្រៅទៅក្នុងសតិអារម្មណ៍មហាជនមិនតិចៗ រឿងនេះជាបញ្ហាសំខាន់ដែលគេត្រូវតែយកចិត្តទុកដាក់ ក្នុងពេលដែលគេសិក្សាពិចារណាការលូតលាស់រីកចំរើន ឬការអន់ថយបែបយ៉ាងណាមួយរបស់ជាតិនិមួយៗជាចាំបាច់ៗ ក្រៅអំពីនេះ គេត្រូវសិក្សាឲ្យបានគ្រប់ផ្នែកហើយយ៉ាងហ្មត់ចត់ទៀត ក្នុងវិស័យអក្សរសាស្ត្រ ដូចជាខាងគំ-នូរ ចម្លាក់ ល្ខោន របាំ ចរិយា... ដែលជាកត្តានាំឲ្យយើងយល់បានច្បាស់ហើយត្រឹមត្រូវ នូវកំរិតវិវត្តន៍របស់គំនិតមនុស្សនូវមនោសញ្ចេតនានឹងសតិអារម្មណ៍ ព្រមទាំងការបលនាខាង

ផ្លូវចិត្តក៏ដូចជាខាងសម្ភារៈរបស់សង្គមមនុស្សក្នុងជំនាន់នោះ ៗ

អក្សរសាស្ត្រមិនអាចជាមាន នៅដាច់ដោយឡែកតែម្នាក់ឯងបានទេ អក្សរសាស្ត្រមានការទាក់ទងជាប់ជិតជិតនឹងសង្គមមនុស្ស ជាក់ស្តែងគឺជាប់នឹងមែកធាងនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច សាសនា ... ។ល។ ដោយសារតែហេតុនេះហើយ បានជាអក្សរសាស្ត្រមានការលូតលាស់រីកចំរើនឬអន់ថយ ... វាស្របទៅតាមសង្គមមនុស្សក្នុងកាលៈទេសៈនិមួយ ៗ ទៅតាមទីទៅទីនឹងគោលបំណងរបស់អ្នកដឹកនាំម្នាក់ៗ និយាយមួយបែបទៀតថា : អក្សរសាស្ត្រវាជាផ្លែផ្កានៃសង្គមមនុស្ស ។ អក្សរសាស្ត្រវាខុសពីវិទ្យាសាស្ត្រនឹងទស្សនវិជ្ជា តែត្រង់រូបភាពនឹងវិស័យមុខជំនាញប៉ុណ្ណោះទេ ឯចំណែកគោលបំណងនឹងអត្ថរស់គឺដូចគ្នាតែមួយ ពីព្រោះវាអនុលោមដូចគ្នាទៅតាមទិន្នាការនៃអ្នកដឹកនាំ ។

# សមាសភាពដើម្បីលាតត្រដាងអក្សរសាស្ត្រ

និយាយរួមៈទៅគឺថាអក្សរសាស្ត្រមានសមាសភាព ៣ យ៉ាង ជាមូលដ្ឋានក្នុងការលាតត្រដាងខ្លួនចំពោះសង្គមមនុស្ស ។

១– សិល្បភាសា ជាមធ្យោបាយមួយអាចធ្វើឲ្យមនុស្សមាន ការរំភើបចិត្ត (ជាប់អារម្មណ៍) បណ្តុះគំនិតមនុស្សឲ្យមានដល់ គ្នានឹងគ្នា ។ ពិសេសគឺសំឡេងដែលគេចាត់ទុកថាជាអាវុធ មួយដ៏សក្តិសិទ្ធក្នុងការណែនាំបំបោសអង្អែល ឬញោះញង់សតិ អារម្មណ៍និងមនោសញ្ចេតនាមនុស្ស .. ។ល។

២– អក្សរជាមធ្យោបាយមួយយ៉ាងសំខាន់ ក្នុងការផ្សាយ ក្នុងការស៊ើបជ្រៅទៅគ្រប់តំបន់ជិតឆ្ងាយ គ្រប់មជ្ឈដ្ឋាននានាទាំង ឆ្លងកាត់ពេលវេលា ឆ្លងកាត់សម័យនីមួយ ៗ ទាំងខ្លីវែងរាប់ សតវត្សក៏បានមិនអាចបាត់បង់ ។

៣– កាយវិការ ភាគច្រើនត្រូវគេប្រើនៅលើវេទិកាដើម្បី ទស្សនាមសភាវៈមួយក្នុងការបង្ហាញ អត្ថន័យ និងជួយ បន្ថែមអត្ថរសឲ្យដល់សំដីនិយាយ ដើម្បីចលនាចិត្តអ្នកមើលឲ្យ

មានការចាប់អារម្មណ៍ រំភើប ទៅតាម មានគំនិតខ្លាំងឡើងៗទៅ តាមគំនិតអ្នកស្ដែង ... ។

## វិធីអនុវត្តន៍

ត្រូវមានវិធីបូកបញ្ចូលរវាងធម្មជាតិ នឹងសិល្បៈ រិះរកគ្រប់មធ្យោបាយដើម្បីពង្រីកការពិត ធ្វើឲ្យការពិតមានសោភ័ណភាព (លំអនឹងពង្រីកការពិត) នឹងមាននាដភាព... ។ រឿងធ្វើឲ្យការពិតបានរីកចំរើនមានសោភ័ណភាព នឹងនាដភាពនេះមិនបានសេចក្ដីថា បេះតែប្រមូលចម្រុះប្របូកប្រឡប់មិនដឹងក្បាលកន្ទុយ ប៉ុតណាប៉ុតណាក៏នោះទេ ផ្ទុយទៅវិញយើងត្រូវបេះជ្រើសរើសយកសកម្មភាពណា នឹងបលនាណា ដែលជាមូលដ្ឋានមានចរិតទូទៅ (a un caractère général) មកលាបប្រេងផាត់ម្សៅ រាំបំពាក់គ្រឿងសិល្បៈឲ្យបានសមរម្យក្នុងស្មារតី បេះបន្ថែមបន្ថយឲ្យល្អ (d'une manière créatrice) ចៀសវាងគំនិតយន្តនិយម (machinisme) ។ បេះជ្រើសរើសករណី ជ្រើសរើសលក្ខណៈ

ទំនងសកម្មភាពណាដែលមានបរិតជាតំណាងឬជាកូនសោ ...
ដែលងាយៗ ហើយសាមញ្ញផងយកមកលាតត្រដាងបង្ហាញមហាជន ប៉ុន្តែមិនត្រូវក្បត់នូវលក្ខណៈពិសេសនៃឯកជនម្នាក់ៗទេ ពីព្រោះលក្ខណៈពិសេសនេះ វាមានគុណភាពអាចនាំឲ្យវណ្ណកម្មអក្សរសាស្ត្រមានសោភ័ណភាព និងមានតម្លៃក្នុងការស្រូបទាញសតិអារម្មណ៍មនុស្សខ្លាំងណាស់ដែរ ។

ត្រូវនាំគំនិតអ្នកអាន ឬអ្នកមើលឲ្យយល់បានត្រឹមត្រូវវត្ថុបំណង និងនាំគេឲ្យទៅដល់ទីដៅ ។

ប៉ុន្តែក្នុងការប្រើពាក្យ ប្រើកាយវិការនិងប្រើសំឡេង ... ត្រូវឲ្យបេះមានការកំណត់ ទន់ភ្លន់ក្រៃលែងគំនិតបញ្ចេញបញ្ចូលអត្ថសេរីនិងអត្ថរូបឲ្យស្របទៅតាមអធ្យាស្រ័យ នៃកាលៈទេសៈ ដើម្បីបលនាយនោះសព្វេគនាអ្នកមើល ឬអ្នកអាន អ្នកស្តាប់ ឲ្យមានការដើរស្របទៅតាមដំណើរនៃវណ្ណកម្មនោះៗ . . . ។ល។

# ការបែងចែកប្រភេទនៃអក្សរសាស្ត្រ

និយាយដល់ការបែងចែកប្រភេទនៃអក្សរសាស្ត្រ យើងយល់ថាក៏មានការស្មុគ្រស្មាញច្រើនណាស់ មានពណ៌សម្បុរ មានរូបភាពច្រើនបែបផែន ។

ក្នុងករណីដែលមានព្រឹត្តិការណ៍ចំឡែក ៗ ជាប្រវត្តិ-សាស្ត្រលេចភ្លឹកម្ដងឡើងជាការវិវត្តន៍ប្រែប្រួលម្ដង ៗ អក្សរ-សាស្ត្រក៏គឺមានការប្រែប្រួលបែងចែកដោយល្អិតល្អន់ ហើយមានបរិតរើសអើង (Distinction) បែកខ្ញែកសន្ទឹកសន្ទាប់ណាស់ទៅទៀតដែរ . . . នេះយើងមិនទាន់និយាយដល់ការប្រឆាំងគ្នាខ្លះទៀតនៅលើសាកលលោក ដែលបានប្រែក្លាយទៅជាសមរភូមិគំនិតពីរឈមមុខទល់គ្នាធ្វើសង្គ្រាមសំឡេងសង្គ្រាមបាក់ការយ៉ាងសាហាវគួរឲ្យស្ញើប ។

ទោះបីរូបភាព ពណ៌សម្បុរអក្សរសាស្ត្រក៏មានច្រើនបែបផែនមែន ប៉ុន្តែយើងអាចចែកវៀងវ៉ាជាវណ្ណកម្មទាំងអស់នោះជាពីរផ្នែក ឬ ជា ២ វិស័យធំ ៗ បានដូចតទៅនេះ ៖

ក– វិស័យពាក្យសម្រាយ

ខ– វិស័យពាក្យកាព្យ និងបទចម្រៀង

ក– វិស័យពាក្យសម្រាយ បណ្ដាវណ្ណកម្មទាំងឡាយដែលនៅក្នុងវិស័យពាក្យសម្រាយធម្មតា យើងអាចបែងចែកចេញជា ២ ផ្នែកទៀតបើតាមទស្សន៍យើងគឺ : ១– វណ្ណកម្មដែលមានចរិតជាទ្រឹស្ដី (Théorie) ២– វណ្ណកម្មដែលមានចរិតជាការអធិប្បាយ (Description) ។

១– ផ្នែកទ្រឹស្ដី រួមមានប្រភេទសិក្សាអប់រំឧបទេស (genre didactique) និងប្រភេទថ្លែងការ (genre oratoire) ។

ប្រភេទសិក្សាអប់រំ(ឧបទេស) ប្រភេទនេះរួមមានបណ្ដាវណ្ណកម្មដែលមានចរិតបណ្ដុះបណ្ដាលការចេះដឹងដូចជាខាងវិទ្យាសាស្ត្រ តក្កសាស្ត្រ ចិត្តសាស្ត្រ ទស្សនវិជ្ជា ចក្រវាឡសាស្ត្រ មានភាសាសាស្ត្រជាដើម... ។ បណ្ដាវណ្ណកម្មដែលមានចរិតឆ្លើយឆ្លងគ្នា រិះគន់គ្នា (ទិទៀន) ខាងផ្នែកអក្សរសាស្ត្រ

ដោយមានគំនិតអប់រំពឹងផ្អែកទៅលើវិធាន (loi) ដែលមានកន្លងមកហើយ និងពឹងផ្អែកទៅលើយោបល់ឯកជនផ្ទាល់ខ្លួន...។ល។ ក្រៅអំពីនេះនៅមានបណ្តា ប្រវត្តិ អក្សរសាស្ត្រដែលជាមេរៀនពីអតីតកាលទុកឲ្យយើងដកពិសោធន៍ក្នុងបច្ចុប្បន្ន ដើម្បីជាគតិតទៅអនាគត ទោះជាគុណវិបត្តិឬគុណសម្បត្តិក៏ដោយ ។ (ដោយពឹងផ្អែកទៅលើវណ្ណកម្ម ដែលមានលក្ខណៈអប់រំតាមមធ្យោបាយសិល្បៈ) ។

## ប្រភេទថ្លែងការ Genre oratoire

១– ប្រភេទថ្លែងការរួមមានការថ្លែងរាប់រៀបសេចក្តី ដែលមានចរិតឃោសនា ឬអប់រំក្នុងវិស័យនយោបាយដឹកនាំ ការថ្លែងក្នុងវិស័យតុលាការនិងក្រិតក្រមច្បាប់ទម្លាប់ជាវិន័យផ្សេងៗ...។ ការថ្លែងប្រដៅ ឃោសនា ការថ្លែងជូនពរស័ក្តិសារធុការក្នុងពេលធ្វើពិធីបដិសណ្ឋារកិច្ច ឬក្នុងឱកាសមានបុណ្យទានអ្វីមួយ ។

២– ផ្នែករាប់រៀបរួមមាន បណ្តាអត្ថបទដែលមានចរិតជាប្រវត្តិសាស្ត្រ និងអត្ថបទដែលមានចរិតជាប្រលោម ។

## រឿងជាប្រវត្តិសាស្ត្រ (ទូទៅ)

បណ្ដាអត្ថបទឬរឿងរ៉ាវវែងខ្លីទាំងឡាយ ដែលមានអត្ថរស សំខាន់ក្នុងការពិចារណាត្រិះរិះ មានការទាក់ទងដល់ព្រឹត្តិការណ៍ វិវត្តន៍ប្រែប្រួលនៃសង្គមមនុស្សនិយាយរួម មានការរាប់រៀប អំពីដំណើរចលនានៃជីវភាពរបស់មនុស្សទាំងខាងស្មារតីក៏ដូចជា ខាងសម្ភារៈក្នុងលក្ខណៈសម័យឬកាលៈទេសៈនិមួយៗ ពោះក្នុង ការតស៊ូដើម្បីបង្កើតសភាវៈថ្មី តស៊ូដើម្បីបំបាត់ចោលសភាវៈ ចាស់ និងការតស៊ូដើម្បីកែក្រុកកុំកំដោះ . . . ។

## រឿងជាប្រលោម (ទូទៅ)

បណ្ដារឿងរ៉ាវទាំងឡាយ ដែលគេណាត់ត្រដាងឡើង ដោយមានបរិតខ្វៅ ខ្វល់ខ្វាយ មានការស្រមើស្រមៃ មាន លក្ខណៈធ្វើឲ្យអ្នកអានឬអ្នកស្ដាប់រើរវាយ, ស្រនេះស្រណោច អាណិតអាណូង មានការចាប់អារម្មណ៍ ការរំភើបចិត្ត (ចលនា បានខ្ទះមនោសញ្ចេតនាអ្នកស្ដាប់) ហើយអាចណែនាំអ្នកអានទីង

អ្នកស្តាប់ឲ្យទៅដល់ទីដៅដែលជាវត្ថុបំណងអាថិកំបាំងនៃផ្ទៃរឿងទៅកថាខានក្ទង ដែលជាទស្សន៍យ៉ាងពិតប្រាកដរបស់អ្នកនិពន្ធទៀតផង (ទោះជាជីវទស្សន៍ក្តី (Conception de la vie) ឬក៏ចក្រវាឡទស្សន៍ក្តី (Conception du monde) ។ និយាយមួយបែបទៀតថា : រឿងប្រលោមគឺជារឿងប្រឌិតឬ រឿងនិទានមួយយ៉ាងមានលក្ខណៈទូទៅ តួអង្គនៃរឿងមានចរិតផ្សេងប្រែងដោយប្រៀបធៀប ដែលគាត់តែងឡើងដោយគំនិតរបស់អ្នកនិពន្ធ ។ ម្យ៉ាងទៀត តួអង្គនៃផ្ទៃរឿងប្រលោមច្រើនតែមានលក្ខណៈជានិមិត្តនៃកាលៈទេសៈ ពេលវេលា ឬ សម័យនីមួយ ៗ ដែលអ្នកនិពន្ធមានការចាប់អារម្មណ៍ទោះជាខាងការឈឺចាប់, ការគោតសរសើរ ឬ ការអបអរ នឹងការផ្ទាក់ដោយ . . . ។ល។

ប្រលោមលោកមានន័យ នឹងរូបភាពច្រើនសន្ធឹកសន្ធាប់ណាស់ អនុលោមទៅតាមជំនាន់ តាមទស្សន៍នឹងតាមលក្ខណៈជីវភាពរបស់អ្នកនិពន្ធដូចជា : រឿងប្រលោមមានចរិតជាប្រវត្តិ

សាស្ត្រ ប្រលោមលោកមានចរិតជាចរិយាប្រដៅសាសនា... ប្រលោមលោកលាតត្រដាងរបបគ្រប់គ្រង បញ្ហាសង្គមមនុស្ស មានការរិះគន់ទំនៀមទំលាប់ មានប្រលោមលោកខ្លះនិយាយតែពីសេចក្ដីស្នេហា (មាតុគ្រាមតញ្ញា) ១ មុខប៉ុណ្ណោះ...ៗ

## រឿងព្រេង (ទូទៅ) Légende

បណ្ដាអត្ថបទរឿងរ៉ាវពីជំនាន់ដើម ដែលនិយាយរាប់រៀបតែពីទេព្ដាឥន្ទ្រព្រហ្មមានការក្សត្រតាជាដើម មានចរិតអស្ចារ្យហួសសម័យ រឿងរ៉ាវជាគំនិតនិយមគ្មានហេតុផល (គំនិតយល់សប្ដិ Utopisme) ហើយពិធីរាប់រៀប ក៏មិនសូវឃើញមានប្រើពាក្យសំដីវោហារឲ្យគេក្បោះក្បាយធំ...ៗ មានរឿងព្រេងមួយពួកទៀតមានចរិតបែបប្រជាមានិត (populaire) ដែលគេហៅថារឿងព្រេងប្រជាមានិត រឿងនេះភាគច្រើនគឺជារឿងអនាមិក (រឿងដែលគ្មានឈ្មោះអ្នកនិពន្ធ) រកឈ្មោះអ្នកដាក់ចេញមិនឃើញ ៗ

ពីដើមមកគេច្រើននិយាយឲ្យគ្នាស្ដាប់តៗ គ្នាពីមនុស្សម្នាក់

ទៅមនុស្សម្នាក់ រឿងគស់តាំងនោះ មានគុណភាពជាក់ស្តែងក្នុង ការដឹកនាំមនុស្ស បលនាមនុស្សសម្បើមណាស់ដែរ ឲ្យមនុស្ស ទៅកាន់សភាពសកម្មទំនឹងរិះគន់ផលសភាវៈដែលមហាជនគួរតាម ក្នុងសម័យនោះគេយល់ថាជាមិនសមរម្យ . . . ។ល។

## រឿងប្រឌិត (និទាន) Conte

រឿងប្រឌិតមានលក្ខណៈប្រែប្រួលទៅតាមប្រភេទ ដូចជា រឿងប្រឌិតមានចរិតជាទស្សនៈវិជ្ជា ជាច្បាប់ប្រៀនប្រដៅ កំប្លែង បំភាសដើម្បីសប្បាយ . . . រឿងព្រេងជាគំនិតនិយមរីករាយ អណ្តែតអណ្តូងគួរឲ្យស្រងេះស្រងោចគួរឲ្យភ្ញាក់ផ្អើល ។ មាន រឿងប្រឌិតខ្លះទៀតមានលក្ខណៈស្លូតត្រង់ ស្រគត់ស្រគំណែនាំ ឲ្យមនុស្សមានសភាពកបសាទីងនឹង . . . ។

## រឿងល្បើក (ទូទៅ) Fable

រឿងល្បើកគឺជារឿងដែលគេលើក គេប្រឌិតឡើងដោយ ការចាប់អារម្មណ៍នៃអ្នកនិពន្ធ ដើម្បីរិះគន់ទំនៀម ដើម្បីសរសើរ

លើកតម្កើង ដើម្បីបង្ហាញគុណសម្បត្តិសការៈមួយ ប្រកបដោយ បរិតកំផ្ទែងកំផុក . . . ។ ក្នុងការពិនិត្យសង្កេតទូទៅភាគច្រើនគេឃើញតួអង្គក្នុងរឿងល្បើក អ្នកនិពន្ធច្រើនយកតិរច្ឆាន យករុក្ខជាតិ ធម្មជាតិនឹងសមិទ្ធផ្សេងៗជាតួអង្គ រូបភាពពិសេសរបស់វាគឺ ជាកាព្យ ឬ ជាឃ្លាងមានពាក្យ ៣, ៤, ៥ . . . ។ល។

## រឿងជាតក (ពិសេសចំពោះអក្សរសាស្ត្រខ្មែរ)

ជាឯកសារ ជារឿងរ៉ាវផ្សេងៗ ដែលនិយាយដល់ការកសាងបារមីរបស់តួអង្គពោធិសត្វ ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត . . នេះបើនិយាយអំពីខាងពុទ្ធនិយម ។ រឿងទាំងនោះសុទ្ធតែពាក់ទងឬបកប្រែចេញមកអំពីគម្ពីរបាលីមានគម្ពីរបញ្ញាស-ជាតក ជាដើម . . . ។ បើនិយាយអំពីព្រហ្មនិយមវិញ គឺជារឿងរ៉ាវដែលមានភាគទងដល់ព្រះជាម្ចាស់ទាំង ៣ អង្គ គឺព្រះព្រហ្ម ព្រះនារាយណ៍ ព្រះឥសូរ. រឿងនិយាយដល់ព្រះនារាយណ៍ទសាវតារ (នារាយណ៍អវតារ ១០ គ្រា) មានរឿងមហាភារត-

យុទ្ធ រឿងកមកើតដោយដើម ដែលជារឿងលាតត្រដាងឡើងនូវសការៈមួយមកផ្ចាញ់ផ្ចាលសការៈតាក្រក់ក្នុងគោលគំនិតការពារវប្បធម៌ពួកជនតារ្យ (នៅប្រទេសឥណ្ឌា) ការពារទឹងឃោសនាឡែលទ្ធិព្រហ្មណ៍ជាន់ដើម ... ។ល។

## រឿងដំណើរ (ថ្មី) Nouvelle

បណ្ដារឿងរ៉ាវដែលមានបរិតជាដំណើរ ការរៀបរៀបប្រកបដោយពាក្យពេចន៍មុឺងម៉ាត់ហ្មត់ចត់ច្បាស់លាស់ទើងមានលក្ខណៈប្រាប់ជាដំណើរ ។

« បណ្ដារឿងរ៉ាវទាំងអស់ដែលបានអធិប្បាយទាន់លើគេតាបសរសេរជារបៀបល្ខោន ជារបៀបដំណើរ ឬ ជារបៀបប្រលោមក៏បាន ... ស្រេចលើការម៉ុនប្រសប់ ងការឈ្លាសវៃរបស់អ្នកនិពន្ធប៉ុណ្ណោះ ក្នុងការបេះផ្ទៃបង្ហាញរឿងនិមួយៗ ដោយតាមរូបភាពណាមួយ » ។

# ១- វិស័យពាក្យកាព្យ

អក្សរសាស្ត្រក្នុងវិស័យពាក្យកាព្យ រួមមានសាស្ត្រច្បាប់ និងសាស្ត្រល្បែងនានា ចម្រៀងវែងខ្លីដែលលាតត្រដាងឡើង នៅគំនិតស្នេហាស្មារតីអប់រំតាមទំនៀមទម្លាប់ប្រពៃណី ចម្រៀងរីករាយសាទរអបអរបន្ទាប់ពីបានទទួលជ័យជំនះអ្វីមួយ ។

## ចម្រៀងស្នេហា

តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាល ចម្រៀង ឬកំណាព្យដែលបានបង្ហាញឡើងនូវមនោសញ្ចេតនាស្នេហាក៏មានសន្ធឹកសន្ធាប់ណាស់ដែរ ។

បើយើងប្រៀបធៀបរវាងសម័យទាំងពីរនេះ យើងអាចយល់ថា :

ក- អតីតកាល = កំណាព្យ ឬ ចម្រៀងខាងផ្នែកស្នេហារវាងប្រភេទ (ប្រុស + ស្រី) ភាគច្រើនមានលាយឡំចម្រុះនៅក្នុងការងាររកសិកម្មរបស់ខ្លួន ហើយមានចរិតបាក់ផ្គត់

នៅតាមទំនៀមទម្លាប់និយមថែមទៅទៀតផង ប៉ុន្តែបើយើងពិចារណាឲ្យជ្រៅជ្រះយើងយល់ថា សភាពស្នេហាជំនាន់នោះមានចរិតសុទ្ធបូតស្មោះត្រង់ខ្លះតាមបែបបុរាណ មានចរិតសង្កត់សង្កិនបង្ខិតបង្ខំខ្លះពីសំណាក់គ្រួសារ . . . ។

១– បច្ចុប្បន្នកាល = សព្វថ្ងៃនេះ ភាគច្រើនបម្រៀងនឹងកំណាព្យបែបស្នេហាវាលេចឡើងពីរផ្នែកប្រឆាំងគ្នា (មិនសូវមានចរិតទំនៀមទម្លាប់ឲ្យហួសហេតុពេកទេ ប៉ុន្តែមានអត្ថបទខ្លះបំរើតែការស្នេហាមួយមុខប៉ុណ្ណោះ) ។ បម្រៀងទាំងកំណាព្យ ១ ពួកបំរើការស្នេហាដែរ ប៉ុន្តែមានចរិតកសាងខ្លះ ១ ពួកទៀតបំរើតែសេចក្តីស្នេហាមួយមុខប៉ុណ្ណោះ យើងអាចហៅថា "ស្នេហាដើម្បីតែស្នេហា" ផ្ទុយគ្នានឹងស្នេហាដើម្បីកសាងស្ថាបនា . . . ។

## បម្រៀងអប់រំ

កំណាព្យផ្សេងៗ ដូចជា "ស្រីបុកស្រូវ" "កូនអើយកើតមេបា ចូររក្សាទៀនចុកនៅ . . ." អប់រំខាងវិស័យសេដ្ឋកិច្ចរបស់

យើងជំនាន់ដើម ចម្រៀងផ្សេងៗទៀតដែលមានចរិតប្រជាមានិតខ្លះ ដូចជាបទបំពេរកូន បទច្រៀងសប្បាយគន្លាប្រុសស្រី... សាស្ត្រា, ច្បាប់ផ្សេងៗ... ភាគច្រើនមានចរិតអប់រំមនុស្សឲ្យមានចរិយាសម្បត្តិមួយយ៉ាង ទន់ភ្លន់តាមទស្សន៍សាសនា ឬទំនៀមទម្លាប់ខាងវិធីបរបោសអង្គ្ឈល ឬវិធីផ្គាប់ផ្គុនគ្នារវាងមនុស្ស ហើយមានការសើរសើងខ្លះៗដែរ...ៗ មានកំណាព្យខ្លះទៀតជាពាក្យភាសិត ឬពាក្យចាស់ មានអត្ថរសសំខាន់ៗដែលលាតត្រដាងឡើងនូវគុណសម្បត្តិ និងគុណវិបត្តិនៃសង្គមជំនាន់នោះ (ដូចជាពាក្យថា ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង...) ៗ

បណ្ដាកំណាព្យ ឬ ចម្រៀងក្នុងអក្សរសាស្ត្រខ្មែរយើងជំនាន់នោះ ក៏មានចរិតអប់រំជាទស្សនវិជ្ជា, ចរិយា, សេដ្ឋកិច្ច, សាសនា មុខជំនាញ...គឺចង់ដែរ ៗ មានការរិះគន់ទំនៀមនេះទម្លាប់នោះ ឬ ក៏កំប្លែងកំផ្លុកក្នុងគោលគំនិតកែប្រែចរិយា (ដូចជាកំណាព្យរាប់រៀបអំពីកាយវិការនៃអ្នកប្រមឹក) ៗ

## វីរកម្មនិទាន ÉPOPÉE

បណ្ដាចម្រៀង ឬ កំណាព្យដែលថ្លែងឡើងបន្ទាប់ អំពីបានជ័យជំនះក្នុងវិស័យអ្វីមួយ ដូចជាពីដើមគេច្រៀងសរសើរទេព្ដាក្នុងពេលធ្វើស្រែបាន បច្ចុប្បន្ននេះមានចម្រៀងអនុស្សាវរីយ៍រំឭកទឹកដល់ជ័យជំនះ បុណ្យទានឬការស្ថាបនាអ្វីមួយ ៗ

# បណ្ដាឫសគល់អក្សរសាស្ត្រនៃជាតិនិមួយៗ

ទោះនៅក្នុងយុគណាក៏ដោយ ពាក្យថា "ជំនាន់, សម័យ ឬ កាលៈទេសៈ" ក៏មានន័យនឹងឥតត្រសទូលំទូលាយណាស់ ហើយមានចរិតទូទៅ មានអាការៈបូករួមបណ្ដាបាតុភូតគំនិតរបស់របស់សង្គមមនុស្សនៅក្នុងពេលនិមួយៗ ថែមទៅទៀតផង ។

ឧទាហរណ៍ដូចជាពាក្យថា "ជំនឿ" ។ ពាក្យថា "ជំនឿ" មួយមាត់នេះ យើងគប្បីយល់ឲ្យទូលាយដូចតទៅនេះថា ៖

មនុស្សយើងជាធម្មតាគេតែងតែមានជំនឿ, ជំនឿដែលគេជឿនោះ មានចរិតស្របទៅតាមសមត្ថភាពរបស់អ្នកដែលគេជឿ ហើយទស្សន៍ដែលគេជឿនោះទៀត ក៏ស្របទៅតាមពេលវេលា ស្របទៅតាមកាលៈទេសៈថែមទៅទៀតផង ... ។ បានសេចក្ដីថា : ក្នុងករណីដែលមានវត្ថុ ឬសភាវៈអ្វីមួយ ពុំមាន (Exister) កើតឡើង មនុស្សគេជឿថា វត្ថុនោះ សភាវៈនោះពុំមានមែនដោយវិចារណញ្ញាណតាមហេតុផល មនុស្សមិនគ្រាន់តែជឿតាមសភាវៈឬវត្ថុអ្វីមួយដែល

មានកន្លងមកហើយនោះទេ សូម្បីតែសភាវៈណាដែលនឹងជាមាននៅក្នុងអនាគត ក៏មនុស្សគេអាចជឿពិតបានដែរ ពីព្រោះមនុស្សក៏ជាសភាវៈមួយ មានការត្រិះរិះពិចារណារកហេតុផល, មនុស្សមានខួរក្បាលចេះរកមធ្យោបាយទប់ទល់នឹងធម្មជាតិ ព្រមទាំងដោះស្រាយធម្មជាតិនិយាយរួម . . . ។

យើងគប្បីពិនិត្យមើលក្នុងវិស័យអក្សរសាស្ត្រ ដើម្បីជាជំនួយដល់ការពិចារណាត្រិះរិះស៊ីជម្រៅឱ្យយល់បាននូវមនោសញ្ចេត-នានឹងទ្រង់ទ្រាយអធ្យាស្រ័យរបស់មនុស្សក្នុងមួយជំនាន់ៗ ។

ហេតុអ្វីបានជាអក្សរសាស្ត្រក្នុងជំនាន់ដំបូងបង្អស់នៅគ្រប់ប្រទេស ក៏មានចរិតអន់ថយនឹងមាននិន្នាការគំនិតនិយម ? (យល់សប្តិនិយម) ។

យើងអាចឆ្លើយដោយលក្ខណៈទូទៅឱ្យទូលាយថា : នេះហើយដែលគេហៅថាសម័យឬកាលៈទេសៈឬជំនាន់របស់សង្គមមនុស្ស ! ។ មនុស្សមិនអាចផ្លាប់បានទេបើមនុស្សមិនខំប្រឹង

ទម្លាប់ ។ ។ ទី ២ ទី ៣ ឬ ទី ៤ គ្មានទេ បើសិនណាហើយគ្មានលើកទី ១ ... ។ ប៉ុន្តែបញ្ហាសំខាន់នៅត្រង់ថា : បើមនុស្សធ្វើការអ្វីមួយខុសក៏មិនទាន់គ្រោះថ្នាក់ប៉ុន្មានទេ គ្រោះថ្នាក់ខ្លាំងតែត្រង់មនុស្សដឹងខ្លួនថា ខុសៈហើយនៅតែមិនព្រមកែ គឺថាបើយើងបេះរកឃើញការខុសហើយ មនុស្សគប្បីយកការខុសនោះមកសិក្សាដើម្បីរកការត្រូវ បើមនុស្សធ្វើបានត្រូវហើយគប្បីយកការត្រូវនោះមកសិក្សា ដើម្បីពង្រីកការត្រូវនោះឲ្យបានធំទូលាយហើយ ឋិតថេរថែមទៅទៀត ... ។ល។

យើងសូមជូនឫសគល់នៃអក្សរសាស្ត្ររបស់ប្រទេសខ្លះៗ ដើម្បីធ្វើជាមូលដ្ឋាន ក្នុងការសិក្សាប្រៀបធៀបរបស់អស់លោកអ្នកអាន ... ។

## ប្រទេសចិនប្រជាមានិត

កាលពីជំនាន់សតវត្សរ៍ទី ៦ ទៅដល់សតវត្សរ៍ទី ១២ មុនគ្រិស្តសករាជ ។ ឿនអក្សរសាស្ត្ររបស់ប្រជាជនចិនគេមានគម្ពីរ

(ឆ្បូ-គីញ) ហៅថា គីញ-ធី សរសេរជាពាក្យកាព្យ ជាចម្រៀងរបស់ប្រជាជនគ្រប់ជនបទសម្រាប់ច្រៀងឆ្លើយឆ្លងគ្នាពីសតវត្សរ៍មួយទៅសតវត្សមួយ . . . ។

គម្ពីរនេះមួយមានជិត ៣.០០០ អត្ថបទនិយាយពីរបៀបអំពី-មនោសញ្ចេតនាស្លូតបូតរបស់ប្រជាកស្ត្រនៅជនបទ លាតត្រ-ដាងឡើងនូវការឈឺចាប់ គ្មានប្រែកបេញរបស់មនុស្សក្នុងជំនាន់នោះ បង្ហាញការព្រួយបារម្ភ, ការខ្វាប, ការក្តៅក្រហាយ, សប្បាយរីករាយ . . . ជាពិសេសក្នុងគម្ពីរនេះមានអត្ថបទនិយាយសរសើរលើកតម្កើងព្រះម្ចាស់សួគ៌ ក្នុងការបន់ស្រន់សុំពរសព្វ-សាធុការ . . . ។

នៅក្នុងសម័យ ខុង-ជឺ Confucius លោកនេះបានពិនិត្យត្រិះរិះមើលក្នុងបណ្តាអត្ថបទទាំងឡាយនៅក្នុងគម្ពីរ ឆ្បូ-គីញ លោក ខុង-ជឺ បានជ្រើសរើសយកប្រហែលជា ៣០០ អត្ថបទប៉ុណ្ណោះ ហើយលោកបានបញ្ចូលទៅរួមទ្រឹស្តីទាំងឡាយដែល

មានអត្ថរសអប់រំមនុស្សជំនាន់នោះ ឲ្យមានគំនិតនឹងអព្យាស្រ័យស្របទៅតាមគំនិតរបស់លោក ។

ក្នុងការប្រៀបធៀប អក្សរសាស្ត្រចិនក្នុងជំនាន់ ខុង-ជឺ មានការល្អគួរសាស់ជឿនលឿនខ្លះដែរខាងផ្នែកគំនិតសម្ភារៈនិយម ប៉ុន្តែចរិតពិសេសរបស់ ខុង-ជឺ គឺជូន់ទៅខាងបរិយាខាងពេក (ស៊ឺតេ, សាន, ចុង) មានវណ្ណកម្មផ្សេងៗ មានស្នាតបំពាក់មនុស្សឲ្យខុបខាបវណ្ណៈខាងក្បូក លើកតម្កើងទំនៀមទម្លាប់ដែលគ្មានហេតុផល ... ដូចជាស៊ីប្ដាយកុំឲ្យអស់ពីឆ្នាំង, ដួសបាយកុំបាំជល់អស់ពីបាន ... គ្មានសមភាពបុរសស្ត្រី ដូចជារបបមានសែ (សែគួច, សែល្អ, សែម៉ៅ ... យកឈ្មោះតាមសែប្រុស) ស្ត្រីគ្មានតម្លៃ មានវិធីប្ដូជាស្ត្រីកាលពីដើមដែរ ... ឥឡូវនេះគេហៅថាសែឧក្បាលទឹក ... ។ល។ រាសនារបស់មនុស្សរស់នៅក្នុងសង្គមត្រូវផ្ញើទៅលើព្រះម្ចាស់សួគ៌ ។

ដល់មកសព្វថ្ងៃនេះ ប្រជាជនចិនបានរុញច្រានខឿនអក្សរ

សាស្ត្ររបស់ជាតិគេឱ្យមានតម្លៃជាអតិបរមា ស្របទៅតាមផលប្រយោជន៍នៃសេចក្ដីត្រូវការរបស់ជីវិតខាងផ្នែកសម្ភារៈ ក៏ដូចជាខាងស្មារតីប្រកបដោយលក្ខណៈ វិទ្យាសាស្ត្រ យ៉ាងសកម្ម... បោះបង់ចោលភាគច្រើន (ជាមូលដ្ឋាន) នូវផ្នត់គំនិតដែលមានជំនឿមិនសមរម្យទឹងទំនៀមទម្លាប់ ដែលមានចរិតយល់សប្តិនិយម គ្មានហេតុគ្មានផល ដែលជាឧបសគ្គដល់ជីវភាពមហាជន...។

## ប្រទេសខ្មែរយើង

ខឿនអក្សរសាស្ត្ររបស់ខ្មែរយើង តាំងពីបុរាណមក និយាយរួម គឺមានទិន្នាការគំនិតនិយមជាមូលដ្ឋានដែលបែកចេញមកពីឥទ្ធិពលនៃអក្សរសាស្ត្ររបស់ជនអារ្យនៃជាតិឥណ្ឌា ។

ឥទ្ធិពលនៃចលនាអក្សរសាស្ត្ររបស់ឥណ្ឌា បានហូរចូលមកប្រទេសខ្មែរ ដោយការផ្សាយសាសនារបស់គេដែលមានចរិតពីរយ៉ាងខុសគ្នា ប៉ុន្តែមានមូលដ្ឋានគំនិតនិយមដូចគ្នា ។

១– អក្សរសាស្ត្រដែលដុះចេញមកពីមជ្ឈ-

ផ្ទានព្រហ្មនិយម បណ្ដារឿងរ៉ាវដែលបកប្រែ ដកស្រង់ ឬនិយាយរួមទៅថា: បណ្ដារឿងរ៉ាវណាដែលមានទាក់ទងដល់ គម្ពីរវេទ ទាក់ទងដល់ការសរសើរលើកតម្កើង ព្រះអាទិទេព ព្រះម្ចាស់សួគ៌មានព្រះត្រីបុតី គឺព្រះនារាយណ៍ ព្រះព្រហ្ម ព្រះឥសូរជាដើម ទាក់ទងដល់ការបន់ស្រន់អារក្សអ្នកតា ខ្មោចព្រាយណ៍ មានបូជាទៀនធូប សែនព្រេន ... យកបុណ្យទានភាពជាមធ្យោ-បាយដោះស្រាយដំណើរជីវិត ... ប្រាសបាកគតិបណ្ឌិត និងសុភទិព្ទ័យដែលជាសត្យាគតិរបស់លោក ដូចជារឿងរាមកេរ្តិ៍ ទិព្វសង្វារ មហាភារតយុទ្ធ ... ជាដើម ។ រឿងអស់ទាំងនេះ គឺជាវណ្ណកម្មផ្នែកព្រហ្មនិយម មានបរិយល់សម្ដិ, មិនជាក់ស្ដែង, អសកម្មទិងមានគុណភាព ការពារផលប្រយោជន៍របស់ពួកអារ្យជនទៃជាតិតំណៀ ។ល។ អក្សរសាស្ត្របែបនេះបានហូរចូលមកប្រទេសខ្មែរយើងតាំងពីមុនសម័យអង្គរម៉្លេះ គឺជាតាំងពីកម្ពុជសតវត្សរ៍ទី ១ ទី ២ ... ។

២- អក្សរសាស្ត្រដែលផុះចេញមកពីមជ្ឈដ្ឋានពុទ្ធនិយម បន្ទាប់ពីព្រហ្មនិយមមក មានបណ្ដាអក្សរសាស្ត្រមួយបែបទៀត មានការប្រសើរជាងមុនច្រើន មានលក្ខណៈណែនាំមនុស្សឲ្យទៅកាន់សេចក្ដីសុខ មានបរតអសកម្មខ្លះ ប៉ុន្តែមានមូលដ្ឋានគំនិតនិយមដូចគ្នា គឺបណ្ដាអក្សរសាស្ត្រដែលមាននិន្នាការពុទ្ធនិយម ចេញមកពីស្រុកឥណ្ឌាដូចគ្នា ប៉ុន្តែបែកជាពីរពួក គឺមានគណៈមហាយានមួយនិងគណៈហិនៈយានមួយ ... ។

ក្នុងវិស័យពុទ្ធនិយមយើងឃើញមានវណ្ណៈកម្មជាច្រើនដែលមានការទាក់ទងដល់គម្ពីរបាលី រឿងដែលដកស្រង់ ឬ ដកប្រែចេញមកពីគម្ពីរព្រះត្រៃបិដកនិងបញ្ញាសជាតកជាដើម... និយាយអំពីការកសាងបារមីរបស់ពោធិសត្វ ដើម្បីបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត និងមាននិន្នាការជូនទៅខាងចរិយាប្រដៅមនុស្សឲ្យបានត្រឹមត្រូវ បាក់ផុតទៅតាមសាសនាឃ្លាតពីផ្លូវលោកខ្លះៗ ... ។

សាសនា ខុង-ជឺ (៥៥៥ - ៤៧៩ មុន គ.ស.) ប្រដៅមនុស្សឲ្យធ្វើទៅខាងចរិយាដែរ ប៉ុន្តែគាត់មិនសូវបានប្រែតប្រៀនចំពោះបុណ្យបាប ក្នុងការកាប់សម្លាប់សត្វជាតុយកមកបម្រើជីវិតពេកទេ បានសេចក្តីថា : ខុង - ជឺ ប្រដៅមនុស្សឲ្យមានគោលគំនិតរបៀបព្រះពុទ្ធដែរខាងចរិយាធម៌ ប៉ុន្តែមានលាយឡំចរិតសេដ្ឋកិច្ចជំនួញ (សម្ភារៈនិយមខ្លះ) ក្នុងការគស្ទើបរើជីវិតរស់នៅ... ។ល។

ក្រៅអំពីពលនាអក្សរសាស្ត្រដែលមាននិន្នាការផ្អែកទៅតាមគោលគំនិតពីខាងលើ ខ្មែរយើងនៅមានធនអក្សរសាស្ត្រពីរបែបផ្សេងទៀតដែលមាននិន្នាការជាជាតិនិយមមួយ ទីងជាបរទេសនិយមមួយ ដែលកើតឡើងអំពីវប្បធម៌របស់ជាតិដទៃដែលគេផ្សាយចូលមក ។

អក្សរសាស្ត្រដែលមាននិន្នាការជាជាតិនិយម (ខេមរនិយម) និយាយរួមទៅគឺបានលាតត្រដាងឡើងនូវព្រឹត្តិការណ៍

នូវខ្សែជីវិតរបស់ជាតិយើងក៏ពិតមែនហើយ ប៉ុន្តែបើយើងពិនិត្យឲ្យល្អិតល្អន់ទៅ យើងឃើញថាមានបរិតពុទ្ធនិយមនិងព្រហ្មនិយមខ្លះៗ លាយឡំគ្នានៅក្នុងនោះ . . . ។ល។ ការនេះជាធម្មតាពីព្រោះថាភាគច្រើនខ្មែរយើងមានឥទ្ធិពល នៃ ចលនាអក្សរសាស្ត្របែបពុទ្ធនិយមនិងព្រហ្មនិយមនេះ សន្ធឹកសន្ធាប់នៅក្នុងគំនិតទៅហើយ ៗ មុនគេថែមទៀតផង ។

ក្នុងសម័យប្រទេសយើងត្រូវពួកអាណានិគមនិយមវាជិះជាន់វប្បធម៌សេរីភាពនិយមរបស់ពួកមានសន្ទុះខ្លាំង ក៏នាំឲ្យអក្សរសាស្ត្ររបស់ខ្មែរយើងមួយផ្នែក មានទិន្នាការទៅតាមពួកវាទៅដែលយើងឲ្យឈ្មោះថា : អក្សរសាស្ត្រផ្នែកបរទេសនិយម ។ ពាក្យថាបរទេសនិយមនេះ គឺមានន័យថាបរទេសប៉ែកខាងលិចច្រើនជាង ពីព្រោះថា បរទេសដែលនៅជិតខាងយើងដូចជាសៀម, យួន, ចិន, លាវ... ។ល។ ក៏ត្រូវទទួលឥទ្ធិពលនៃវប្បធម៌បរទេសបស្ចិមនិយមដូចយើងដែរ ។

និយាយសង្ខេបទៅថា: អក្សរសាស្ត្រខ្មែរយើងមាននិន្នាការ ៤ បែប ឬថាការចលនានៃអក្សរសាស្ត្រខ្មែរយើងបានទទួលឥទ្ធិពល ៤ យ៉ាង ដែលជានិន្នាការវិវត្តទៅតាមកាលៈទេសៈនិមួយៗ ៗ

ក្នុងសម័យនេះ នគរយើងបានឯករាជ្យ ខឿនអក្សរសាស្ត្ររបស់ជាតិយើងមានសន្ទុះយ៉ាងច្រើន ដោយប្រៀបធៀបពីអតីត-កាល ៗ បណ្ដាវណ្ណកម្មយ៉ាងសន្ធឹកបានផុះឡើងបន្តបន្ទាប់គ្នា មានចរិតចម្រុះ (mixte) មានលក្ខណៈនយោបាយ, សេដ្ឋកិច្ច, វប្បធម៌, សង្គមកិច្ច. . . (លោកិយសច្ចៈ) ប្រទាញប្រទង់មនុស្សណែនាំមនុស្សឲ្យទៅតាមនិន្នាការនៃអ្នកសរសេរ ប៉ុន្តែទោះបីយ៉ាងណា និយាយរួមទៅខឿនអក្សរសាស្ត្ររបស់ខ្មែរយើងក្នុងសម័យនេះក៏មានចរិតជាក់ស្ដែង, មានលក្ខណៈវិទ្យាសាស្ត្រច្រើនក្នុងការបំរើសង្គមមនុស្សតាមលោកិយសច្ចៈ. . . ។ល។ គឺជាអក្សរសាស្ត្រដែលចាប់ផ្ដើមមានមូលដ្ឋានជាសម្ភារៈនិយមហើយ ។

# ប្រទេសឥណ្ឌៀ

តាំងពីដើមមក ប្រទេសឥណ្ឌៀមានរឿងអក្សរសាស្ត្រផ្នែកខាងគំនិតនិយមមិនអន់ណាស់ដែរ ពិសេសគឺប្រទេសឥណ្ឌៀនេះហើយដែលជាអ្នកផ្សាយឥទ្ធិពល នៃវប្បធម៌គំនិតនិយមចំពោះទ្វីបក្រៅ ដោយនិយាយរួមទៅ ។

ឥណ្ឌៀគេចូលចិត្តកាន់សាសនានិងជឿទៅតាមលទ្ធិ ដែលមានព្រះត្រីបុតី គឺព្រះព្រហ្ម, ព្រះវិស្ណុនិងព្រះសិវៈជាតំណាង ប៉ុន្តែមនុស្សដែលចូលចិត្តគោរពច្រើន (បើយកមធ្យម) គឺគណៈព្រះវិស្ណុ (ព្រះនារាយណ៍ ឬ ហៅថាព្រះម៉ែ) ។

រឿងរ៉ាវជាអក្សរសាស្ត្រក្នុងវិស័យលទ្ធិនេះ ច្រើនតែចុះចេញមកអំពីគម្ពីរវេទ ។ វេទប្រែថាចេះដឹង ។ អត្ថបទនៅក្នុងគម្ពីរវេទនេះមានកត់សំគាល់នូវពាក្យ (សំដីជាធម៌គាថាសម្រាប់សូត្ររបស់ប្រជាជនគេ) (មានអ្នកប្រវត្តិសាស្ត្រខ្លះបាននិយាយថា: គម្ពីរឈ្មោះវេទនេះ ជាឈ្មោះលទ្ធិមួយមានមុនលទ្ធិព្រហ្ម

ចាប់កំណើតដំបូងនៃបន្តុំសំនៅស្រុកអេហ្ស៊ីប ដែលនិយមការបូជាយកទេព្តាខ្មោចព្រាយជាធំ គោរពសក្ការគាជាធំ... មិនមែនយកព្រះត្រីមូត្តិជាធំទេ) ។

គម្ពីរវេទមាន ៤ ក្បាលធំ ៗ ប៉ុន្តែដោយក្បាលទី ៤ មានក្រោយគេ ហើយគេហៅតមុនមកតែបី ម្ល៉ោះហើយគេច្រើនហៅថាវេទបីទៅ (ត្រៃវេទ) ។

គម្ពីរវេទ ឬហៅថា សាសនាវេទនេះ គឺជាសាសនាមួយការពារផលប្រយោជន៍របស់ជនអារ្យៈនៅប្រទេសឥណ្ឌា កើតចេញមកពីជំនឿរបស់មនុស្សចំពោះព្រះអាទិទេព (ទេវៈ) ដែលគ្មានរូបពិតប្រាកដឋិតនៅគ្រប់កន្លែងនៃលោកសន្និវាស... ។ល។

ត្រៃវេទ = វេទ ៣

១— ឫគវេទ Rig véda កើតប្រហែលជា ១០០០ ឆ្នាំមុន គ. ស. គម្ពីរនេះនិយាយច្រើនអំពីតែវិធីបូជា យេជ្ញ (យជ្ញ) បូជាព្រះឥន្ទ្រ ។

(គុន៍ការរំឮកគុណ, លើកតម្កើង ឬសរសើរ) ។

២— យជុរវេទ Yadjour véda និយាយពប់របៀបអំពីវិធី

បូជា យជ្ញ.

៣— សាមវេទ Sâma véda សរសេរជាពាក្យកាព្យ

និយាយច្រើនតែអំពីពិធីបូជាទេព្តា . . . ។

៤— អថវវេទ Atharwa véda (ខ្មែរហៅក្លាយទៅជា

មេគាថាដែលនាំឲ្យសាបមន្តអាគម) ។

តាមការពន្យល់របស់សាសនានេះ គេនិយាយថា: ព្រះ

អាទិទេពបានប្រទានគម្ពីរទាំងនេះ (គឺព្រះនារាយណ៍) ឲ្យមក

ព្រះមនូ (មនូប្រែក្លាយជាមនុស្ស) ព្រះមនូនេះបានពន្យល់ឲ្យដល់

ពួកតាបសឫសី តាបសឫសីបានពន្យល់ដល់ពួកព្រាហ្មណ៍ ។

ប៉ុន្តែមានពួកមនុស្សអាក្រក់ គឺយក្សពិពាធថាបេះតែមកលួចយក

គម្ពីរនេះបានជាបេះតែមានរឿងច្បាំងគ្នាមិនឈប់ តួយ៉ាងដូចជា

រឿងនារាយណ៍ទសាវតារ មានរឿងមស្យាវតារ (ត្រី) កុរមាវតារ (អណ្ដើកកូរទឹកអម្រឹត) ព្រះរាមបន្ទូននឹងវាមនាវតារ (ព្រហ្មតឿ) សុំដី ៣ ជំហានក្នុងរឿងត្រីវិក្រម . . . ។ល។ ជាដើម ។

តាមការពិនិត្យរួមចំពោះគម្ពីរវេទទាំងនេះ យើងអាចយល់បានដោយធ្វើការសង្កេតដូចតទៅ :

ក្នុងវិស័យសង្គមកិច្ច : គម្ពីរទាំងនេះបានកត់ត្រាទុកបែលនានយោបាយដែលមានដំណើរជាប្រវត្តិសាស្ត្រនឹងសង្គមកិច្ចនៃពួកជនអារ្យ (Aryens) ។ ចំណែកខាងជំនឿវិញ គម្ពីរទាំងនេះបានលាតត្រដាងយ៉ាងច្បាស់នូវគុណភាពរបស់ព្រះព្រហ្ម ព្រះនារាយណ៍នឹងព្រះឥសូរ (ត្រីមុតិ) ។ បើនិយាយខាងអក្សរសាស្ត្រវិញ គម្ពីរទាំងនេះបានបង្ហាញឲ្យយើងឃើញនូវសភាពឈឺចាប់, កំសត់ទុគ៌ត មានចរិតក្ដាប់មុខ (fanatique) ក្នុងការបំរើសេចក្ដីប្រាថ្នាដែលខ្លួនមានជំនឿ ក្លាហានក្នុងការអនុវត្តន៍តាមមនោសញ្ចេតនារបស់ខ្លួនក្នុងជំនាន់នោះ ដែលខ្វះការពិចារណាយ៉ាងខ្លាំង . . . ។

បន្ទាប់ពីអក្សរសាស្ត្រផ្នែកព្រហ្មនិយមមក នៅប្រទេសឥណ្ឌា ក៏ចាប់ផ្តើមមានចលនាអក្សរសាស្ត្រផ្នែកពុទ្ធនិយមទៀត ដែលមាននូវមូលដ្ឋានគំនិតនិយមដូចគ្នា ៗ ផ្នែកខាងនិន្នាការនៃអក្សរសាស្ត្រពុទ្ធនិយមនៅប្រទេសឥណ្ឌា មានបរិតនឹងសភាពប្រហែលគ្នានឹងស្រុកខ្មែរយើងដែរខាងមូលដ្ឋាន ខុសគ្នាតែត្រង់នៅប្រទេសឥណ្ឌា ប្រជាជនគេកាន់ច្រើនសាសនាណាស់ ហើយសាសនានិមួយ ៗ ក៏មានច្រើននិកាយថែមទៀតផង ។ គ្រាន់តែសាសនាព្រះពុទ្ធតែមួយ ប្រជាជនគេជឿហើយកាន់ទម្លាប់ផ្សេង ៗ គ្នាដល់ទៅ ៧១ និកាយ ហេតុនេះយើងឃើញថានៅស្រុកឥណ្ឌា ខឿនអក្សរសាស្ត្ររបស់គេក៏មានបរិតប្របូកប្របល់មិនសូវឯកភាពប៉ុន្មានដែរ ... ។

ករណីបណ្ដាវណ្ណកម្មដែលមាននិន្នាការជាពុទ្ធនិយមយើងអាចសង្ខេបយកខ្លឹមសារបានដូចតទៅនេះ ។

អក្សរសាស្ត្រទាំងនោះ ប្រដៅមនុស្សឲ្យស្គាល់ច្បាស់យ៉ាង

ណាដែលហៅថាច្បាប់កម្ម-ផល អន្ទោលតាមប្រាណ ក្នុងវដ្ដ-សង្សារដែលគេថាជាកន្លែងទុក្ខ ប្រដៅមនុស្សឲ្យយល់ការពិត ៤ យ៉ាង (អរិយសច្ចៈ ៤ Les quatre vérités) ដែលជាមាគ៌ាដឹកនាំមនុស្សទៅកាន់បានបរមសុខ គឺព្រះនិព្វាន (កន្លែងដែលគ្មានកើតស្លាប់តទៅទៀត) ។

ក្នុងការសង្ខេបអត្ថសេចក្ដីនៃបណ្ណាវណ្ណកម្មទាំងនោះ យើងឃើញថា : គោលគំនិតសំខាន់ៗ គឺពន្យល់មនុស្សឲ្យយល់ថា វដ្ដសង្សារ គឺជាសមុទ្រទុក្ខនៃសត្វលោក (កើត, ចាស់, ឈឺ, ស្លាប់) ដរាបណាសត្វលោកនៅមានកើតស្លាប់តទៅទៀតដរាបនោះ សេចក្ដីទុក្ខរបស់សត្វលោកនេះតែបន្តគ្មានទីបំផុត (វិលចុះវិលឡើង) ដោយសារចំណងនៃតណ្ហា Passion (ចង់រស់, ចង់ល្អ, ចង់សប្បាយ, ចង់មាន...) ចង់ភ្ជាប់នឹងសម្ភារៈខាងក្រៅ (ពណ៌សម្បុរ, ទជាស, រូបភាព . . .) របស់អាត្មន Atman គឺរូបអញ ។

ក្នុងការសង្កេតអាត្មា, អាត្មន, អញ, រូប le moi នេះ ឲ្យជ្រៅទៅទៀត យើងឃើញថា: បើសិនណាជា "អញ" នេះ បន្តចំណាន់ក្នុងជីវិតតទៅទៀត ។

មិនគ្រាន់តែក្នុងមួយជាតិអញនេះប៉ុណ្ណោះទេ ដែលត្រូវទទួលទុក្ខក្នុងវដ្តសង្សារ សូម្បីតែជាតិផ្សេងៗ ដែលបន្តពីអញនេះទៅទៀត ក៏ត្រូវតែទទួលរងទុក្ខមិនចេះអស់មិនចេះហើយដែរ ពីព្រោះគេយល់ថា: លោកគឺទុក្ខ រស់ក្នុងលោក គឺរស់ក្នុងទុក្ខ ហេតុនេះ បើចង់ផុតទុក្ខត្រូវរកផ្លូវចេញឲ្យផុតពីលោក គឺឋានដែលគ្មានលោក គ្មានរូប សូន្យ ឬ ហៅថាព្រះនិព្វាន . . . ។ គេយល់ថា ការកើតស្លាប់របស់មនុស្សអន្ទោលទៅវិលចុះវិលឡើង ដូចជាកង់រទេះ អស់មួយជុំនៅមួយជុំ . . . មិនមែនស្លាប់ទៅសូន្យឈឹងនោះទេ គឺថាស្លាប់ទៅហើយតែមកចាប់កំណើតឡើងវិញ (មនុស្សដែលមកចាប់កំណើតនោះមិនមែនមនុស្សថ្មីទេ គឺមនុស្សចាស់ៗ ដែលបានស្លាប់ពី

មុខ) ។ អ្នកខ្លះទៀតយល់ថា : វដ្តសង្សារគឺជាកន្លែងមានស្លាប់នឹងមានកើត ។ យើងយល់ពាក្យថា "មានស្លាប់នឹងមានកើត" ខុសគ្នានឹងពាក្យថា "ស្លាប់ហើយមកចាប់កំណើតកើតម្ដងទៀត" ។

គេយល់ថា : ទុក្ខវេទនារបស់មនុស្សជាតិនេះ គឺជាផលនៃកម្មរបស់មនុស្សពីជាតិមុន បើមនុស្សប្រព្រឹត្តអំពើអ្វីមួយដែលគេហៅថាអាក្រក់នៅក្នុងជាតិនេះ អំពើអាក្រក់នេះនឹងទៅជាផលវិភាគនៃសេចក្ដីទុក្ខឲ្យយើងទៅជាតិក្រោយ ... ។

មនុស្សរស់នៅក្នុងវដ្តសង្សារ ដរាបណាមិនទាន់ចេះរកផ្លូវបំបាត់ទុក្ខបាន គឺថាបំបាត់តណ្ហា ដរាបនោះទុក្ខចេះតែអន្ទោលតាមព្រាណាមិនចេះអស់ ... ។

បំបាត់តណ្ហានៅក្នុងទស្សន៍ពុទ្ធនិយម មិនបានសេចក្ដីថាត្រូវតែរំលាយខន្ធ (រំលាយខ្លួន) ឲ្យបាត់ (គឺស្លាប់) នោះទេផ្ទុយទៅវិញ គឺត្រូវចេះត្រិះរិះពិចារណាតាមផ្លូវសីល, សមាធិ,

បញ្ញា . . . តាំងចិត្តឲ្យនៅជាកណ្តាល គ្មានជាប់ទីងសភាវៈអ្វីទាំងអស់ (មេត្តា) ។ បានសេចក្តីថា តាំងចិត្តជាកណ្តាល គឺគ្មានការរំភើបចំពោះវត្ថុ ចំពោះសភាវៈអ្វីទាំងអស់ ទោះបីជីវិតខ្លួនក៏ដោយ . . . ។ ខាងលើនេះជាការសង្កេតក្នុងអតីតកាល ចំណែកឯជឿនវប្បធម៌ក្នុងសម័យបច្ចុប្បន្ននៃប្រជាជនឥណ្ឌៀ ក៏កំពុងតែមានសន្ទុះច្រើន ដូចជាប្រទេសនានាដែលគេកំពុងកសាងថ្មីអ៊ីចឹងដែរ ពោះបើនៅទទួលឥទ្ធិពលពីជឿនវប្បធម៌របស់ពួកបស្ចិមប្រទេសខ្លះៗ នៅឡើយក៏ដោយ . . . ។ល។

## ប្រទេសជប៉ុន

ក្នុងការប្រៀបធៀប ប្រជាជនជប៉ុនក៏កាន់សាសនាដែលមានបរិតគំនិតនិយមមិនអន់ណាស់ដែរ ដូចជាសាសនាយ៉ាតូ សាសនាព្រះពុទ្ធផ្នែកមហាយាន . . . ។ ហេតុនេះយើងអាចយល់បានថា ជឿនអក្សរសាស្ត្ររបស់ប្រជាជនជប៉ុនក៏មាននិន្នាការគំនិតនិយមបែបព្រហ្មបែបព្រះពុទ្ធស្រដៀងទៅនឹងខ្មែរ, ចិន, យួនលាវ . . . អ៊ីចឹងដែរ ។

ក្នុងគម្ពីរកូស៊ីគី KOJIKI (គឺជាក្រាំងកត់សំគាល់នូវរឿងព្រេងផ្សេងៗ ពីបូរាណរបស់ប្រជាជនជប៉ុន) ដែលជាសៀវភៅកត់រៀបព្រឹត្តិការណ៍តាំងពីយុគកើតទឹកកើតដីថាមានប្រព័ន្ធទេវតា ៧ អង្គតាមទស្សន៍ជំនាន់នោះរបស់ជាតិគេ ។

គម្ពីរតាំងនោះបានបង្ហាញឲ្យយើងឃើញថា : កាលដើមឡើយមានបងប្អូនពីរនាក់ ១. ឈ្មោះអ៊ីសាណាស៊ី IZANAGI ១ ទៀតឈ្មោះ អ៊ីសាណាមី IZANAMI ត្រូវបញ្ជូនពីស្ថានលើ (ព្រះអាទិទេព) ជាឲ្យចុះមកបង្កើតនគរជប៉ុន ។ បងប្អូនទាំងពីរនាក់នេះបានយកគ្នាជាប្ដីប្រពន្ធ ក្នុងករណីអកុសលប្អូនត្រូវស្លាប់មុនទៅ បំណែកឯបងនៅរស់ម្នាក់ឯងស្រណោះស្រណោចសោកស្ដាយខំដើរទៅគ្រប់ទីកន្លែងដើម្បីរក ប៉ុន្តែមិនប្រទះសោះ ។ ក្នុងពេលចុះទៅងូតទឹកជម្រះកាយនៅក្នុងទន្លេ បងនាងនោះចេះតែយំសោក... ដល់ពេលឡើងមកលើគោកឯមាត់ច្រាំងវិញ ទឹកសំអាតដែលហូរចេញមកពីនេត្រប្រមុះក៏ក្លាយទៅជាទេវតាគំណាន

ផ្គរលាន់ ឬ រន្ទះបាញ់ – ទឹកភ្នែកខាងឆ្វេងក្លាយទៅជាព្រះអាទិត្យ ទឹកភ្នែកខាងស្តាំក្លាយទៅជាព្រះច័ន្ទ . . . ។ល។ ក្រៅពីនេះ នៅក្នុងគម្ពីរនោះមានកត់សំគាល់រឿងពីរផ្សេងៗ ជាច្រើនទៀតដែរ ដែលមានបរិតលើកតម្កើងសាសនាគេ ឬជាព្រះអាទិត្យ ដែលមានព្រះអាទិទេព មីកាដូ ជាតំណាង (Shintoisme) ទឹងពុទ្ធសាសនាផ្នែកអច្ចរិយបាទដែរ . . . ។

## បទចម្រៀង Chansons de geste របស់បារាំង

ពាក្យថា geste នេះមានន័យថា : អំពើជ័យជំនះជីវភាពនៃវីរបុរសទាំងឡាយ តាមពាក្យ gesta ។

Chansons de geste នេះ គឺជាបទចម្រៀងជ័យជំនះ (ÉPOPÉE) មួយបែបមានបរិតលើកតម្កើងសរសើរបណ្តាជ័យជំនះដ៏ក្លាហានប្រកបដោយពលីកម្មនៃបណ្តាវីរបុរស ប៉ុន្តែមានពណ៌សម្បុរបែបទេវតានិយម ឬ ជាគំនិតយល់សប្តិនិយមខ្លះៗ . . ។ល។

ចម្រៀងទាំងនោះមាន ៣ ប្រភេទ គឺ: ចម្រៀងវីរភាពនៃសាឡឺម៉ាញ ចម្រៀងវីរភាពនៃហ្គីយ៉ូមដូរ៉ង់ Guillaume d'orange ហើយនិងចម្រៀងវីរភាព នៃ ដុងម៉ាយ៉ង់ Don Mayence ។

## ភាសិតនិងចម្រៀងរបស់វៀតណាម

ចម្រៀងនិងភាសិតរបស់ជនជាតិវៀតណាម គឺជាកម្រងពាក្យដែលគ្មានវគ្គ គ្មានជំពូកឲ្យប្រាកដប្រជាទេ ។

អត្ថរសនិងគុណភាពរបស់ចម្រៀងនិងភាសិតទាំងនោះមានបរិតហ៊ឹកហ៊ឺនមនុស្សឲ្យកាន់ចរិយាធម៌ត្រឹមត្រូវ ឲ្យមានសភាពទន់ភ្លន់ក្នុងការរស់នៅរាប់អានគ្នាទៅវិញទៅមក ។ ខៀនអក្សរសាស្ត្រទាំងមូលរបស់ជនជាតិវៀតណាម និយាយរួមទៅ គឺមិនខុសពីអក្សរសាស្ត្ររបស់ចិនប៉ុន្មានទេ ខាងរូបភាពក៏ដូចជាមូលដ្ឋាន ។ កាលពីដើមមុននឹងមានអក្សរ គុក-ងឺ (គឺអក្សរវៀតណាមសព្វថ្ងៃនេះ) ជនជាតិវៀតណាមប្រើអក្សរ "ហាន" (គឺអក្សរចិន) ។ វៀតណាមត្រូវចិនជិះជាន់អស់រយៈ

ពេលយ៉ាងយូរទៀតផង ហេតុនេះយើងអាចសន្និដ្ឋានបានថា : ខឿនវប្បធម៌តាំងមូលរបស់វៀតណាម គឺជាខឿនវប្បធម៌របស់ចិនអីចឹងដែរ ។ ម្យ៉ាងទៀត ពាក្យខ្មែរយើងហៅថាយួនៗនេះក៏វាមានឫសគល់ជាប្រវត្តិសាស្ត្រទៀត គឺថាកាលពីដើមយួននេះគឺជាជនជាតិមួយ ដែលខ្លាតមកពីស្រុកយុនណាន់ YUNNAN ប្រទេសចិនខាងត្បូង ហេតុនេះហើយភាគច្រើនទំនៀមទម្លាប់ចិននិងវៀតណាម គឺតែមួយមានអធ្យាស្រ័យដូចគ្នា (ថ្ងៃចូលឆ្នាំ, វិធីសែនព្រេន, ដាក់ឈ្មោះកូនទៅយកសែតាមខាងប្ដី . . .។ល។) និយាយសង្ខេបទៅ អក្សរសាស្ត្រ, ខឿនវប្បធម៌, សាសនា . . . របស់ជនជាតិចិន និងវៀតណាមមានសភាពប្រហាក់ប្រហែលគ្នាណាស់ បើយើងយល់អក្សរសាស្ត្រវៀតណាមច្រើន គឺយើងអាចយល់លក្ខណៈអក្សរសាស្ត្រចិនបានច្រើនដែរ ហើយខាងមូលដ្ឋាន...។

## ម៉ាឡាយូ

ខឿនអក្សរសាស្ត្រប្រជាមានិតរបស់ជនជាតិម៉ាឡាយូ រួម-

មានៈពាក្យបណ្តាំទូន្មាន ដែលជនជាតិម៉ាំឡាយជឿថា ជាពាក្យមានអច្ឆរិយភាពខ្លាំងពូកែសក្តិសិទ្ធិអាចជួយខ្លួនឲ្យធ្វើបាន ។

<u>ចម្រៀង</u> = ចម្រៀងទាំងនោះមានចរិតលើកសរសើរព្រះអាទិទេព ទឹងលាតត្រដាងថ្វាយព្រះអាទិទេពឲ្យយល់បាននូវសភាពជីវិតយ៉ាប់យ៉ឺនរបស់ខ្លួន . . ។

<u>ពាក្យបួងសួង</u> = មានពាក្យបួងសួងសុំសេចក្តីសុខសេចក្តីចំរើនពីទេព្តា ខ្មោច អារក្ស អ្នកតា . . . ។

<u>ចណ្ឌាកម្មបទ</u> = មានពាក្យពោល ឬ ជាបទចម្រៀងមានចរិតដាក់ទោសដល់អំពើខុសទាំងឡាយណា ដែលខ្លួនបានប្រព្រឹត្តក្នុងពេលធ្វើវត្ត ទឹងក្នុងពេលដែលខ្លួនបន់ស្រន់ស្នើសុំពរស័ក្តិសារធុការពីខ្មោចព្រាយណ៍ ទេព្តា . . . ។

# អក្សរសាស្ត្របៀបបុរាណ Classique

អត្ថន័យ – អក្សរសាស្ត្របៀបបុរាណ (ពិសេសនៅប្រទេសអឺរ៉ុប) គឺជាវិជ្ជាការអក្សរសាស្ត្រមួយយ៉ាងដែលត្រូវរៀបមករករបៀបសរសេរលោតត្រដាង សតិអារម្មណ៍ បែបផែនគន្លង ក្រិតវិន័យតាមរបៀបពីដើម ... ។

នៅប្រទេសបារាំង បលនាអក្សរសាស្ត្របុរាណនេះមានលេចឡើងនៅក្នុងសតវត្សរ៍ទី ១៧ គឺជាអក្សរសាស្ត្រមួយយ៉ាងដែលត្រូវរៀបមកយកបែបបទចាស់ពីដើម នៃ វប្បធម៌របស់ជនជាតិក្រិក-ឡាតាំង ។ នៅស្រុកខ្មែរយើង ទោះបីជាបលនាអក្សរសាស្ត្របុរាណបែបខាងលើនេះ ពុំមិនសូវមានលក្ខណៈលេចឡើងដោយច្បាស់លាស់ គួរឲ្យយើងបង្គ្រងបានដោយជាក់លាក់ អាចចាត់ទុកថាជាបលនាមួយដ៏គ្រប់គ្រាន់ដូចជាប្រទេសគេបាន ប៉ុន្តែយើងក៏មានឥទ្ធិពលអក្សរសាស្ត្របែបបុរាណសន្ធឹកណាស់ដែរដែលត្រូវទទួលមកពីប្រទេសឥណ្ឌា ប្រទេសចិន ... ។ល។

ចលនាអក្សរសាស្ត្របារាំងបែបបុរាណ :

យើងអាចបែងចែកចលនាអក្សរសាស្ត្របារាំងបែបបុរាណជា ៣ បំណែក (ជំនាន់) យ៉ាងច្បាស់លាស់ គឺ:

១- សម័យមុនរបៀបបុរាណ ១៦០០ - ១៦៥៩.

២- សម័យរបៀបបុរាណ ១៦៥៩ - ១៦៨៧.

៣- សម័យរបៀបបុរាណត្រូវអន់ថយ ១៦៨៧ - ១៧១៥.

បណ្តាការពិសេសៗ នៃចលនាអក្សរសាស្ត្រនេះ គឺ:

ក- ខាងផ្លូវចិត្តនិងខាងចរិយា គឺថាត្រូវតែប្រព្រឹត្តឲ្យបានត្រង់ត្រឹមត្រូវតាមគន្លងនៃខឿនរបៀបធម៌ជំនាន់ ក្រិក - ឡាតាំង ។ បណ្តាឧទាហរណ៍រឿងរ៉ាវ ឬ ជាវណ្ណកម្មផ្សេងៗ ក្នុងជំនាន់នោះ វាមានតម្លៃតែនៅក្នុងផ្នែកអក្សរសាស្ត្រប៉ុណ្ណោះទេ បំណែកឯខាងផ្នែកសតិអារម្មណ៍ ការណែនាំមនុស្ស . . . គឺនៅតែយកស្មារតី នៃ សាសនាព្រះយេស៊ូជាមូលដ្ឋានដដែលក្នុងការនិពន្ធរឿងរ៉ាវផ្សេងៗ . . . ។

គេយកសម្មាមតិ (**Raisonnement**) ជាធំជាក់ពីលើមនោសញ្ចេតនា (**Sentiment**), ក្នុងការនិពន្ធគេមិនសូវមានឃើញស្មារតីអាត្មានិយមពេកទេ, គាត់ច្រើនក្នុងបណ្ដាវណ្ណកម្មទាំងនោះ អ្នកនិពន្ធ សុទ្ធតែប្រគល់ពាក្យសំដីនិយាយឲ្យទៅតួអង្គ ដែលជាបុគ្គលិកសំដែងរឿង ។

ពាក្យសំដីវោហារត្រូវឲ្យស្អួតបួតគួរសម, និយាយរើសមុខឲ្យច្បាស់ ផ្អែមល្ហែម បបោសអង្អែលលើកដាក់... ត្រូវចៀសវាងពាក្យសំដីណាដែលថ្លែងការណ៍ពិតដោយស្ទងពេក ។

បើរឿងល្ខោនវិញ ត្រូវគេធិប្បាយសំដែងឡើងឲ្យស្របទៅតាមក្បួនដែលគេហៅថា «ត្រីសណ្ឋាន» ឬថា «ឯកភាព ៣ យ៉ាង» **trois unités** គឺ :

១ – ឯកភាពទីកន្លែងដែលកើតមានរឿងនិមួយ ៗ **Unité de lieu.**

២ – ឯកភាពពេលវេលាដែលកើតមានរឿងនោះ **Unité de temps.**

៣- ឯកភាពបលនានៃផ្ទៃរឿង **Unité d'action** គ្រប់ប្រភេទវណ្ណកម្មត្រូវតែកញ្ចក់ឲ្យច្បាស់លាស់ រឿងស្នេហាមិនត្រូវឲ្យលាយឡំនឹងជ័យជំនះវីរភាព **ÉPOPÉE** រឿងចុកកំផ្លែង (Satirique) មិនត្រូវឲ្យលាយឡំ ប្រឡូកប្រឡល់នឹងរឿងអត្ថាធិប្បាយ . . . ។ល។

យូរៗមានផ្នែកវណ្ណៈខ្លាំងពូកែមានស្ដេចនាម៉ឺនជាដើមផ្ដៀតឱកាសដើម្បីពង្រឹងឫទ្ធិអំណាចរបស់ខ្លួន ពួកកវីនិពន្ធសិល្បករក៏ប្រែក្លាយខ្លួនទៅជាពួកចុកកំផ្លែងកំប្រៀង បណ្ដាវណ្ណកម្មទាំងនោះគ្មានចរិតប្រជាមានិត គឺជាជាវណ្ណកម្មដែលលើកសរសើរវណ្ណៈខ្លាំងពូកែ . . . ។ល។

# អក្សរសាស្ត្របែបបុរាណរបស់ខ្មែរយើង

ដើមទន្ទឹមគ្នានឹងរឿងអក្សរសាស្ត្ររបស់ប្រជាជនយើង ពីសម័យដើម (សម័យមុនលទ្ធិព្រាហ្មណ៍ចូលស្រុក) កាលនោះខ្មែរយើងមិនទាន់មានអក្សរទេ គេច្រើននិយាយផ្សាយតៗគ្នា តាមមាត់ទទេ ។ ចលនាអក្សរសាស្ត្របែបបូរាណដែលផ្សាយចេញមកពីឥណ្ឌា ក៏ចាប់ផ្ដើមមានឥទ្ធិពល ដោយមុនដំបូងប្រើអក្សរជាសំស្ក្រឹត (នៅលើសិលាចារឹក) កត់ត្រាសំគាល់ហេតុភេទ ឬ ព្រឹត្តិការណ៍ផ្សេងៗ ជាអក្សរសំស្ក្រឹត ។

លោកស៊ុដេស ចាងហ្វាងសាលាបូព៌ាប្រទេសបារាំងបានឲ្យដឹងថា: ភាសាសំស្ក្រឹតជាភាសាអ្នកប្រាជ្ញសម្រាប់ធ្វើបញ្ជីកត់ត្រារឿងហេតុរបស់ស្ដេច (នៅឥណ្ឌា គេយកទៅប្រើសម្រាប់ជនការ) សេចក្ដីដែលតែងជាភាសាសំស្ក្រឹតសុទ្ធតែរៀបរៀងជាពាក្យកាព្យ មានក្បួនខ្នាត ក្រិត្យក្រមទន់ភ្លន់ត្រឹមត្រូវ . . . ។

វណ្ណៈកម្មផ្សេងៗ ច្រើននិយាយសរសេរលើកតម្កើងវណ្ណៈខ្លាំងពូកែដែលចម្លងចេញមកពីប្រទេសឥណ្ឌា ដូចជារឿង

នារាយណ៍ទសាវតារ... ជាដើម យកមធ្យោបាយកាប់សម្លាប់ មានមន្តអាគមតាមគម្ពីរវេទ ។

បន្ទាប់ពីនោះមកក៏មានអក្សរសាស្ត្របែបបុរាណ ដែលផ្សាយជាភាសាមគធៈទៀត ដូចជារឿងជាតកនៅក្នុងគម្ពីរបាលីបុរាណ... ។ យកច្បាប់កម្មផល loi de la causalité ដោះស្រាយសេចក្ដីសុខទុក្ខ យកធម៌ខន្តីមកទប់ទល់នឹងការវេទនាលំបាកនឹងយកលទ្ធិសន្តិភាពនិយមមកដោះស្រាយ ទំនាស់តាមពុទ្ធសាសនា... ។

ក្រៅអំពីនោះ រឿងបែបបុរាណដែលមានបរិតប្រជាមានិតគំសន្និកណាស់ដែរ រឿងទាំងនោះមិនសូវមានតម្លៃជាអក្សរសាស្ត្រទេ ពីព្រោះពីដើមមកគេមិនសូវមានកត់ត្រាជាសៀវភៅឬក្រាំងផ្សេងៗ រឿងទាំងនោះគេច្រើននិយាយប្រាប់គ្នាតៗ តាមមាត់ ហើយរកអ្នកនិពន្ធក៏មិនឃើញផង ។ ប៉ុន្តែ ទោះបីឃ្លា-ឃ្លោងមិនសូវបានត្រឹមត្រូវ គ្មានលក្ខណៈអក្សរសាស្ត្រ ក៏ដោយ

ក៏រឿងទាំងនោះក៏មានអត្ថរស គឺជាតម្លៃសតិអារម្មណ៍ល្អប្រើទក្នុងការណែនាំមនុស្សទៅរកសេចក្ដីសប្បាយ សេចក្ដីសុខ ហើយមានសេរីភាពទៀតផង ដូចជារឿង "សិស្សនឹងគ្រូ, រឿងឪពុករើសកូនប្រសា, អាឡេវ, ធនញ្ជ័យ ... ។ល។

# ការបដិវត្តន៍អក្សរសាស្ត្រ

ក្នុងករណីមានការប្រែប្រួលធំដុំជាប្រវត្តិសាស្ត្រខាងអន្តការនយោបាយ, អន្តការសេដ្ឋកិច្ចនិងវប្បធម៌សង្គមកិច្ចផ្សេងៗ . . . ការប្រែប្រួលខាងអក្សរសាស្ត្រក៏គេឃើញមានលេចឡើងដែរ ។

នៅប្រទេសបារាំង ការបដិវត្តន៍អក្សរសាស្ត្រមានកើតឡើងនៅក្នុងសម័យវឌ្ឍនិវត្តន៍ **Epoque de la Renaissance** ក្នុងសតវត្សរ៍ទី ១៤, ១៥ បន្ទាប់មកទៀតដល់ការកែប្រែសាសនា ដល់ការចលនាអក្សរសាស្ត្រមហាវិជ្ជាសមោធានជំនាន់ **Diderot**.

នៅប្រទេសចិន ការបដិវត្តន៍អក្សរសាស្ត្រមានលេចឡើង បន្ទាប់ពីការបដិវត្តន៍នយោបាយឆ្នាំ ១៩១២ រំលំពួក ម្រៀវ-ម៉ាន់-ជាន់ ។ បន្ទាប់មកមានអស់លោក ហោ - ទី និង គួច-ម៉ាកញៀក ធ្វើបដិវត្តន៍អក្សរសាស្ត្រ និងពង្រីកពង្រឹងថែមបន្តបន្ទាប់គ្នា . . . ។

នៅសូវៀត បន្ទាប់ពីបដិវត្តន៍ខែ ១០ មក នៅប្រទេស

មាឡាយូ បន្ទាប់ពីឆ្នាំ ១៨៩០ នៅវៀតណាម មកដល់កម្ពុជឆ្នាំ ១៩១៨ និងនៅប្រទេសខ្មែរយើង បន្ទាប់ពីសង្គ្រាមលោកលើកទី ២ មក ។

## លក្ខណៈពិសេសនៃការបដិវត្តន៍

បដិវត្តន៍អក្សរសាស្ត្រមិនមានន័យថាបង្កើតបលនា អក្សរសាស្ត្រក្ដុងក្ដាំងក្នុងមួយពេល ហើយមានចរិតឯកជនទាំងពួកទាំងក្រុមនោះទេ និយាយដល់ការបដិវត្តន៍អក្សរសាស្ត្រ គឺយើងត្រូវនិយាយដល់មហាជនទាំងអស់គ្នា មានគំនិតកែប្រែក្នុងរយៈមួយយ៉ាងវែង ធ្វើឲ្យអក្សរសាស្ត្រមានលក្ខណៈស្របនឹងការទាមទាររបស់មនុស្ស ស្របនឹងសមត្ថភាពរបស់ប្រជាករ ។ល។ មានសតិអារម្មណ៍ជឿនលឿន មានគំនិតដឹកនាំទៅរកសុភមង្គល នឹងវិធីប្រើពាក្យពេចន៍ងាយៗ មានចរិតប្រជាមានិត ។

## ទិសដៅនៃការបដិវត្តន៍ = ទិសដៅនៃការបដិវត្តន៍អក្សរសាស្ត្រនៅពេលកន្លងទៅជិតៗនេះ គឺ :

— ដើម្បីវាយបំបាត់វិធីចាស់ ( បំបាត់របៀបសរសេរវែងបានសេចក្តីតិច រឹតត្បិតពាក្យសំដីតាមពួកអភិជន ។

— ដើម្បីពង្រីកការសរសេរនិពន្ធមានបរិតប្រជាមានិត បំរើមហាជនទូទៅ . . . ។

— ដើម្បីវាយបំបាត់គំនិតលាតត្រដាងការពិត តែមិនហ៊ាននិយាយចំៗ ( និយាយវិលវង់ ) តាមរបៀបបុរាណចរិត . . .

littérature classique.

— ដើម្បីពង្រីកឡើងអក្សរសាស្ត្រលោកិយសច្ចៈ និយាយការពិត (Vérisme) ដោយរបៀបសរសេរថ្មី រៀបរាប់ច្បាស់ជៀនលៀនហើយស្មោះត្រង់ . . . ។

— ដើម្បីវាយបំបាត់គំនិតការសាយធ្វើឲ្យលំបាក, ( មានការប្រើពាក្យពិបាកយល់ដល់មហាជន ) ពិបាកយល់ដោយប្រើពាក្យមិនទូទៅ ។

– ដើម្បីពង្រីងរៀនអក្សរសាស្ត្រជាតិ មានបរិគសង្គម និយម មានលក្ខណៈទូទៅ ហើយក៏ស្អាង . . . ។

និយាយរួមទៅគឺថាៈ បែបនិយាយ របៀបសរសេរតាម វិធីកែប្រែថ្មី គឺថាងាយយល់, ច្បាស់លាស់, មិនសូវមានពាក្យ ពិបាក ងាយជ្រួតជ្រាបស៊ីជម្រៅទៅដល់មហាជនពលករ . . . ។ កាលណាមានការប្រែប្រួលក្នុងសង្គមម្ដង ៗ ការប្រែប្រួលនេះ ក៏មានគុណភាពធ្វើឲ្យសតិអារម្មណ៍របស់មហាជនបានល្អលាស់ បេះដូងថែមនូវព្រឹត្តិការណ៍ផ្សេងៗ, បលនាបាននូវគំនិតបង់បេះ ដូងខាងវិស័យនយោបាយ ដែលជាកត្តាមួយជួយជម្រុញរៀន អក្សរសាស្ត្រឲ្យបានជឿនលឿនថែម ដែលជាហេតុនាំឲ្យខ្លួន កាន់តែភ្ញាក់រឭកនូវផលប្រយោជន៍ជាតិបានច្រើនឡើង ។

# ចលនាអក្សរសាស្ត្រតាមទំនើង ?

អត្ថន័យ = ពាក្យថា "តាមទំនើង" (Baroque) មកអំពីពាក្យអេស្ប៉ាញ៉ុល (Espagnol) ថា Barucco មានន័យថា "ស្មុញស្មាញ ឬ ក្រវើមក្រវ៉ម" ។

អក្សរសាស្ត្រតាមទំនើងមានគោលបំណងប្រឆាំងនឹងស្មារតីវិធីសាស្ត្រឯកទិស (១) វេយ្យាករណ៍និយមពេករឹតត្បិតតៀតបង្អៀតបង្អល់ក្នុងអក្សរសាស្ត្រ ដើម្បីរំដោះឲ្យមនុស្សនូវសេរីភាពខាងស្មារតីក៏ដូចជាខាងមនោសញ្ចេតនា... ឲ្យទាន់ល្បឿនសិល្បៈក្នុងជំនាន់វុឌ្ឍនិវត្តន៍ (Renaissance) នៅប្រទេសបារាំងក៏ដូចជាប្រទេសអ៊ីតាលីក្នុងសម័យសតវត្សរ៍ទី ១៥, ១៦ ។

ឧបហេតុ = ហេតុដើមដែលនាំឲ្យមានជាព្យាករណ៍ចលនាអក្សរសាស្ត្រតាមទំនើង, មកអំពីខ្សឹនអក្សរសាស្ត្រវេយ្យាករណ៍និយម (២) វិធីសាស្ត្រឯកទិសដែលរឹតត្បិតបង្ខិតបង្ខំសេរីភាពនៃការនិពន្ធរបស់ពួកកវីសិល្បករអក្សរសាស្ត្រ ។

១– ចេះតែដើរតាមគ្នាតាមទិសតែមួយ ។

២– វេយ្យាករណ៍ហួសពេក ។

មកអំពីជឿនវិទ្យាសាស្ត្ររីកចំរើន បាននាំមកឲ្យមនុស្សជំនាន់នោះនូវស្មារតីស្រេកឃ្លានសេរីភាព ស្មារតីលំដោះគំនិតសិក្ខាបទនិយម (Dogmatisme) ។

– មកអំពីចលនាវិឡូនិវត្តន៍មានសន្ទុះខ្លាំងរាលដាលទៅគ្រប់វិស័យ . . ។ មានអ្នកណានាំវង់បុរីដូចជាលោក Le correge Raphaël Michel Ange . . . មុនដំបូងរីកចំរើននៅស្រុកអ៊ីតាលីក្នុងចំណោមពួកសាសនាកដូចជាប្រជារាស្ត្រខាងក្រៅ ។

<u>វត្ថុបំណង</u> = ចលនាអក្សរសាស្ត្រតាមទំនើងមានគោលបំណង :

១– ខាងវិស័យសតិអារម្មណ៍ គឺគោរពតាមរបៀបបូរាណជំនាន់ក្រិក-ឡាតាំង ដើម្បីស្វែងរកតម្លៃនៃសេរីភាពនៅក្នុងអក្សរសាស្ត្រ ។ តែឲ្យទាន់ល្បឿនវិទ្យាសាស្ត្រ ដើម្បីធ្វើឲ្យមនុស្សមានសេរីភាពក្នុងការពង្រីកសម្មាមតិ (Raisonnement) សេរីភាពឯកជន និងសេរីភាពខាងជំនឿ . . . ល។

២– ក្នុងវិស័យមនោសញ្ចេតនា គឺណែនាំចិត្តឲ្យបេះ

ស្រឡាញ់ធម្មជាតិ ស្វែងរកសោភ័ណភាពខាងសម្រស់ធម្មជាតិ មនោសញ្ចេតនាបានដោះស្រាយ ។ សិល្បៈមាននាទីថ្លៃថ្នូរ បានបួលផ្ញើអន្តរាគមនៅគ្រប់វិស័យនយោបាយ, ទស្សនវិជ្ជា, សេចក្តីស្នេហានិងជីវភាពរាល់ថ្ងៃនៃសង្គម... ។ ម្យ៉ាងទៀត ត្រូវឲ្យមនុស្សមានសេរីភាពក្នុងការបួលចិត្តតាមទំនើងនៃឯកជន មានសេរីភាពក្នុងការបង្កើត ឬ ស្ថាបនា មានសេរីភាពបណ្តុះអារម្មណ៍ឲ្យមនុស្សទៅវិញទៅមក ។

និយាយសង្ខេបមកគឺថា "បណ្តាថាមពលរបស់មនុស្ស" ជាទីបំផុតគប្បីបានមកជាកម្មសិទ្ធិនៃឯកជនម្នាក់ៗ, ពង្រីកសេរី-ភាពឯកជនឲ្យដល់កម្រិត មនុស្សត្រូវប្រើគ្រប់មធ្យោបាយដើម្បីត្រឡប់មករកសោភ័ណដ៏ឯក (សោភ័ណនិយម) តាមបែបឡង់-សុង (Lanson). ។

<u>មធ្យោបាយអនុវត្តន៍</u> = ដើម្បីអនុវត្តឲ្យបានតាមគោលបំណងរបស់ខ្លួន អក្សរសាស្ត្រផ្នែកទំនើបនេះ បានដាក់និតិការនិពន្ធដូចតទៅ ;

— និពន្ធរឿងជ័យជំនះ  វីរភាពមានចរិតក្លាហានដើម្បីលើកតម្កើងវីរភាពខ្មែរជំនាន់បុរាណ ។

— ចម្រៀងប្រឌិតឡើង (ចម្រៀងរាប់រៀប) មានចរិតលើកតម្កើងវីរភាពពលករ  វីរភាពតាមទំនើង ... ។

និពន្ធអត្ថបទមានលក្ខណៈរិះគន់ដល់ទម្លាប់ចាស់ដើម្បីធ្វើឲ្យមនុស្សសប្បាយនឹងជិនឆ្អន់ផ្លាស់របៀបពីដើម ... ។

— និពន្ធអត្ថបទទិទៀនដល់អក្សរសាស្ត្រសុចរិត នឹងសច្ចៈធម៌ ។

— និពន្ធបទចម្រៀងពិរោះៗ យ៉ាងស្រងេះស្រងោចអន្ទង់អន្ទោច  អណ្ដែតអណ្ដូងនៅក្នុងពួកសាសនា  ក៏ដូចជាប្រជាករខូចទៅ ។  ប៉ុន្តែបន្ទាប់មកបណ្ដាមជ្ឈជននយោបាយទាំងឡាយបានកៀតខកាសល្អក់យមំបាក់បលនាអក្សរសាស្ត្រធន់ “តាមទំនើង” នេះឲ្យបរាជ័យទៅ ។

ក្នុងករណីត្រូវពួកទស្សនវិទូ  នឹងពួកខេត្តានិយមប្រឆាំង

ទប់ទល់យ៉ាងខ្លាំងគ្រប់វិស័យនយោបាយ, សេដ្ឋកិច្ច, សតិអារម្មណ៍, វិទ្យាសាស្ត្រ . . . ពួកវណ្ណៈខ្លាំងពូកែមានគ្រួសារអភិជន នាមុន ស្តេចបានធ្វើឲ្យចលនាអក្សរសាស្ត្រ "តាមទំនើង" នេះក្លាយទៅជាសភាវៈបុរាណហួសសម័យ (Rococo) ហើយនៅទីបំផុត ចលនាបែប "ទំនើង" នេះ Baroque ក៏ទុកនាំឲ្យចលនាអក្សរសាស្ត្របែបប្រលោម (សេរីភាពនិយម) Romantique បន្តបេសកកម្មជំនួសតទៅទៀត ។

# អក្សរសាស្ត្រប្រលោមលោក (Romantique)

# ឬ អក្សរសាស្ត្រសេរីនិយម (Libertin)

អត្ថន័យ = អក្សរសាស្ត្រប្រលោមលោកមានចរិត ៤ យ៉ាងជាមូលដ្ឋាន គឺ. មានលក្ខណៈស្នេហា, ទាក់ទងដល់មនោសញ្ចេតនា, ឯកជននិយម និងមានចរិតនាំឲ្យអ្នកអានស្រវឹងប៉ូលចិត្ត ។ លក្ខណៈពិសេសរបស់វាគឺស្នេហា និយាយអំពីការលោតត្រដាងនូវមនោសញ្ចេតនាទាំងអស់ដែលកប់ពួននៅក្នុងចិត្ត ហេតុដូច្នេះ អក្សរសាស្ត្របែបប្រលោមលោកមាននិតិការលោតត្រដាងបង្ហាញចេញមកក្រៅ នូវមនោសញ្ចេតនា នូវបណ្ដាសមានចិត្តនៃបុគ្គលនិមួយៗ និងបណ្ដាសោភ័ណភាពល្អស្រស់ត្អូរជាទីចាប់អារម្មណ៍ខ្លាំង ៗ

ខាងផ្នែកទប់ទល់ អក្សរសាស្ត្រប្រលោមលោកមានអាកប្បកិរិយាប្រឆាំងជំទាស់ទីបណ្ដារូបភាព វិធីអក្សរសាស្ត្ររិតត្បិតជំនាន់បុរាណ ខាងផ្នែកអត្ថរស ចលនាប្រលោមលោកបានលំដោះឲ្យមនុស្សមានមនោសញ្ចេតនាសេរីភាព គ្មានការរិតត្បិត

តាមទម្លាប់ ឬ វិធីនិយម និយាយមួយបែបទៀតថា: ចលនាប្រលោមគឺជាមធ្យោបាយជាបឋមមួយយ៉ាង ក្នុងការឈានឲ្យទៅដល់ចលនាជាក់ស្តែងនិយម (Réaliste) និងធម្មសច្ចៈក្នុងអក្សរសាស្ត្រ Vérisme ព្រមទាំងលទ្ធិពិសោធន៍និយម ក្នុងវិទ្យាសាស្ត្រ . . . ។

បណ្តាអ្នកទិទៀនបានធ្វើអត្ថាធិប្បាយ ចំពោះចលនាប្រលោមលោកថាជាអក្សរសាស្ត្រ:

- ធ្ងន់ទៅខាងមនោសញ្ចេតនាពេក ភ្លេចឯខាងសម្មាមតិ (Raisonnement) ។

- ធ្ងន់ទៅខាងឯកជនពេក ភ្លេចឯខាងសង្គមជាតិ ។

- ធ្ងន់ទៅខាងគំនិតគិតស្រមៃ imagination ពេក ភ្លេចឯការជាក់ស្តែង ។

- ធ្ងន់ទៅខាងធម្មជាតិពេក ភ្លេចឯការតស៊ូក្នុងសង្គមមនុស្ស ។

គេអាចចែកចលនាអក្សរសាស្ត្រប្រលោមលោកជា ២ ប្រភេទផ្សេងគ្នា :

១– ប្រលោមលោកជឿនលឿន = ទោះបីមានបរិតស្នេហាខ្លះ ប៉ុន្តែគេយកស្នេហាជាមធ្យោបាយចលនាចិត្តមនុស្សឡើងបំរើការចលនារបស់សង្គមនិយាយរួម គឺមានជីវភាពខាងស្មារតីក៏ដូចជាខាងសម្ភារៈរបស់សង្គមជាដើម . . . ។

២– ប្រលោមលោកពុករលួយ = ដើរតាមផងទង់ស្នេហាដើម្បីស្នេហា បុគ្គលនិយម មានបរិតលយធាយពាសពលទឹកគ្មានសម្មាមតិ Raisonnement អ្នបន្តិចសោះគង់ការអប់រំកសាង . . . ។

មានអ្នកខ្លះឡើងន័យប្រលោមលោកថែមមួយប្រភេទទៅទៀត គឺជា « ប្រលោមលោកបដិវត្ត (Romantisme Révolutionnaire) ។ បើតាមលោកមហាកវីរុស្ស៊ីកន្លៅម្នាក់ឈ្មោះ ម៉ាក់ស៊ុំមគ្គគី Maximegorki លោកនេះមានយោបល់ថាចលនា

អក្សរសាស្ត្រប្រលោមលោក គឺគ្រាន់តែជារូបភាព ១ បែប នៃខ្លឿនអក្សរសាស្ត្រធម្មសច្ចៈរបស់សង្គម (Réalisme social) ប៉ុណ្ណោះទេ ... ។

## ចលនាប្រលោមលោកនៅបស្ចិមប្រទេស

ចលនាអក្សរសាស្ត្រនេះរីកចំរើនឡើងតាមល្បឿននយោបាយសេរីនិយម តាមខ្លឿនសេដ្ឋកិច្ច ឧស្សាហកម្មសេរីនិយម ក្នុងករណី ដែលវិទ្យាសាស្ត្រចាប់ផ្តើមលូតលាស់ជាបឋម ។ រុស្សូ J.J. Rousseau ជាពលករដើមដំបូងក្នុងការលើកទង់និងការរៀបចំឲ្យបានជាប្រភេទមួយ ដែលហៅជាប្រពន្ធប្រលោមលោក (Système romantique)

ចាប់ផ្តើមពីពេលនោះមក ចលនាប្រលោមលោកចេះតែរីកចំរើនមានសន្ទុះយ៉ាងខ្លាំង ហៀរហូរចូលទៅក្នុងវិស័យវេទិការសិល្បៈ និងដូរ្យតន្ត្រី ... ។ Lamartine, Alfret de Vigny, Victor Hugo, Alfret de Musset អ្នកដើរឯកទាំងនេះបានចូលក្នុងផ្លូវប្រលោមលោកនៅបស្ចិមប្រទេសមុនគេបង្អស់ ។

# ចលនាប្រលោមលោកនៅប្រទេសខ្មែរយើង

ចលនាប្រលោមលោកមានកប់ពួន នៅក្នុងខឿនអក្សរសាស្ត្ររបស់ជាតិយើង តាំងពីសម័យបុរាណមក គឺថាចាប់តាំងពីក្នុងកម្លុងសតវត្សរ៍ទី ១៧ ម្ល៉េះ ប៉ុន្តែជាពិសេសរឿងប្រលោមតាំងនោះមិនសូវមានចរិតជាតិទេ ភាគច្រើនគឺបកប្រែ ឬ ដកស្រង់ចេញមកអំពីឯកសារគម្ពីរផ្សេងៗ មានគម្ពីរតាមបែបព្រហ្មសាសនានិងពុទ្ធសាសនាជាដើម ... ។ ប៉ុន្តែដល់មកពាក់កណ្ដាលសតវត្សរ៍ទី ១៨ ក៏មានលេចឡើងដោយច្បាស់លាស់នូវចលនាប្រលោមលោកខ្លះៗ ដែលមានលក្ខណៈជាតិពិតប្រាកដ ដូចជារឿងទុំ-ទាវ ចៅមាស ... ។ល។

ចលនាអក្សរសាស្ត្រខ្មែរផ្នែកប្រលោមលោក មានរូបរាងច្បាស់លាស់មានអត្តស់ជឿនលឿនខ្លះ ក្នុងការប្រៀបធៀបជាមួយនឹងរឿងបុរាណ គឺចាប់តាំងពីក្បាលសតវត្សរ៍ទី ២០ មក ទោះបីពួកអាណានិគមនិយមបារាំងរាំងរិតម៉ូងសកម្មភាព ខ្ទប់មាត់ខ្ទប់ច្រមុះយ៉ាងណាក៏ដោយ ។

## ចលនាអក្សរសាស្ត្រក្រមាប់កំប្លែង Satirique

គោលបំណង= ទិសដៅនៃចលនាអក្សរសាស្ត្រនេះ គឺរកមធ្យោបាយលាតត្រដាងនូវការអាក្រក់, ការខុសឆ្គាំឆ្គង, ការកាន់ប្រឡំជាគុណវិបត្តិនៃមនុស្សដទៃដោយស្វាបញាការ ពាក្យសំដីមានចរិតលេងកំប្លែងសើចសប្បាយ ឬ ទ្រគោះទ្រគើខ្លាំង ដោយសំនួនវោហារក្នុងបទរិះគន់ ដើម្បីកសាងកែប្រែ ឬ ដើម្បីបង្អាប់ផ្ចាញ់ផ្ចាល ... ។

## ការបែងចែកចលនាអក្សរសាស្ត្រក្រមាប់កំប្លែង

អនុលោមទៅតាមតម្លៃនៃការស្តែងលាតត្រដាងចិត្តសាស្ត្រនឹងតម្លៃគំនិតក្នុងការជួយកែប្រែអប់រំគ្នាទៅវិញទៅមក គេអាចចែកចលនាអក្សរសាស្ត្រនេះជា ៤ ប្រភេទ ដូចជា :

១- ប្រភេទក្រមាប់ Satire= គឺជាវិធីក្រមាប់ដោយប្រើពាក្យប្រាសផ្ទេះយ៉ាងស្ទូង ដើម្បីលាតត្រដាងពុតអាក្រក់ បង្ហាញគំនិតថោកនៃអ្នកណាមួយ ក្នុងគោលបំណងសំអុយមនុស្សមានទោសនឹងបង្កើតមេរៀនឲ្យមនុស្សជុំវិញ ដែលជា

ឥទ្ធិពលល្អរបស់ខ្លួន . . . ។ ហេតុដូច្នេះ អ្នកនិពន្ធប្រភេទដៀលត្មះត្រូវយល់ឲ្យអស់យ៉ាងច្បាស់ នូវគុណវិបត្តិនិងចំណុចខ្សោយនៃប្រធាន ដើម្បីរកវិធីបញ្ចេញបញ្ចូលក្នុងការអធិប្បាយ កុំឲ្យមានការញ៉េញ៉ើតញ៉េញ៉ើមអោះអុញ . . . ។

២– ប្រភេទឧបផ្អាប់ Farce = មិននិយាយឲ្យចំការពិតទាំងស្រុងពេកទេ និយាយតែគុណវិបត្តិតូចតាច បញ្ចិតបញ្ចៀង ប៉ុន្តែមានធ្វើកាយវិការឬទឹកមុខក្លះៗ បែបស្អុយ ប្រកបដោយចរិតគួរឲ្យអស់សំណើច . . . ។ វិធីនេះស្រាលជាងវិធីដៀលត្មះ ព្រោះក្នុងការរិះគន់ផ្ចាក់ដូចជាការកសាងអប់រំ . . . ។

៣– ប្រភេទចំអកដុញផ្ទាល់ Ironie = ធម្មតាច្រើនប្រើគំនិតដុយចំអកដុញផ្ទាល់នៅក្នុងឃ្លាដៀលត្មះ បានសេចក្ដីថា: បញ្ចិតបញ្ចៀងនិយាយរឿងនេះ នាំឲ្យរន្ធើរដល់រឿងនោះ និយាយឯជើងនាំឲ្យឈឺដល់ឯត្បូង . . . ។

វណ្ណកម្មប្រភេទនេះ ទើបនឹងមានភ្លាមឃើញបែបដូចជា

ផ្តេសផ្តាសស្តុកស្តឹង ប៉ុន្តែដល់យល់ឲ្យជ្រៅទៅ, ពិនិត្យឲ្យដល់ទៅទើបឃើញថាស្នើងជូរចត់គួរឲ្យសើច, គួរឲ្យឈឺចាប់អន្ទះលោមះទៅតាមសមត្ថភាពនៃអ្នកស្តាប់ ឬ អាន . . . ។ កាលណាយើងប្រមូលបានអត្ថន័យមក ទើបឃើញអត្ថរសដ៏អស្ចារ្យលេចឡើង ។ ហេតុនេះហើយ អ្នកនិពន្ធប្រភេទនេះត្រូវបេះស៊ីជម្រៅ មានពិសោធន៍ច្បាស់លាស់ យល់ឲ្យទូលាយហើយមិនភ្ញាក់ផ្អើលចិត្តស្រាល . . . ។

៤ – ប្រភេទសិល្បគតិ **Esprit** = ត្រឹមត្រូវទឹងជឹង

មានគតិបណ្ឌិត ។ អ្នកនិពន្ធប្រភេទនេះមានទស្សនទូលាយទូទៅចំពោះករណីអ្វីមួយ ច្រើនគិតគូសទាញស្របតាមផ្លូវចិត្តតាមផ្លូវមនោសញ្ចេតនា បែបដូចជាប្រភេទភាសិត ឬ ពាក្យចាស់ទូន្មាន . . . ។ មានជួនកាលអ្នកនិពន្ធដាក់ចេញជាពាក្យមានចរិតជាវិធាន **(loi)** ឬ ជាច្បាប់របស់សង្គម ដោយសារការពិសោធន៍ពីមុនមកថែមទៀតផង ។ និយាយសង្ខេបទៅគឺថា :

ប្រភេទចំអក និងប្រភេទសិល្បគតិមានសភាពទឹងធឹង ស្ងាត់ស្ងៀម សប្បាយរីករាយតែស៊ីដក្រៅ ៗ ប្រភេទដៀលត្មះមានសភាព ឈឺចាប់ដូចចាក់ក្ដៅក្រហាយ . . . ប៉ុន្តែនិយាយរួមទៅ គឺមាន អត្ថន័យ ៖

- ជ្រាលជ្រៅជាងចលនាបែបប្រលោមលោក,
- មានការរិតត្បៀតបែបបទស្រាល ជាងប្រភេទសច្ចៈនិយម (Réalisme) ច្រើន
- បែបថ្មីជាងប្រភេទរិះគន់ទាំងទៀត ៗ

# អក្សរសាស្ត្រតាមនិន្នាការអត្ថភាពនិយម Existentialisme

និន្នាការតាមបែបនាអត្ថភាពនិយមបានផុះពន្លកពីយូរមក-ហើយ ៗ លោក J. P. Sartre បានឲ្យន័យថា: ក្នុងសតវត្សទី ១៨ Diderot, Voltaire, Kant អ្នកទាំងនេះមានទស្សនអត្ថភាពនិយមបានទាត់ចោលគំនិតសាសនានិយម ។ រហូតមកដល់ពាក់កណ្ដាលសតវត្សទី ២០ (១៩៣៩-១៩៤៥) ទើបលោកហ្សង់-ប៉ូល-សាត្រ (J. P. Sartre) បានពង្រីកឡើងដោយប្រភពទស្សនវិជ្ជា និងអក្សរសាស្ត្រយ៉ាងហ្មត់ចត់ ។

គោលបំណង= នៅក្នុងបណ្ដាវណ្ណកម្ម បាតដៃក្រខ្វក់

---

"Les Mains Sales" "Les Jeux sont Faits" "La P . . . Respectueux" ពិសេសក្នុងសៀវភៅ "សត្ត" និង "សូន្យ" ។

ទ្រឹស្ដីអត្ថភាពនិយម គឺជាលទ្ធិមនុស្សនិយម (ប្រឆាំងនឹងលទ្ធិគំនិតនិយមជំនាន់បុរាណ) Anthropologisme J. P. Sartre បានបញ្ជាក់ច្បាស់លាស់ថា "យ៉ាងណាដែលហៅថា អត្ថភាព-និយម ?" ។

– គឺសភាវៈទាំងអស់សុទ្ធតែមានពីរផ្នែកសំខាន់ គឺ : វត្ថុធាតុ (Essence) និងការធរមាន (Existence) ។

វត្ថុធាតុរួមមានបណ្ដាសភាវៈទាំងអស់ដែលមិនប្រែប្រួលរបស់មនុស្ស ការរស់មានជីវិត (ធរមាន) គឺជាសភាវៈមួយដែលមាននៅក្នុងបច្ចុប្បន្ន ។ សាសនា, ទស្សនវិជ្ជា, ទំនៀមទម្លាប់ ហើយពិសេសបណ្ដាអ្នកចេះដឹងទាំងអស់នៅមហាវិទ្យាល័យ ស៊ក-បោន Sorbonne ក៏សុទ្ធតែទទួលស្គាល់ថា : វត្ថុធាតុមានមុនជីវិតដែរ ។ ហេតុនេះមនុស្សត្រូវខ្វល់ខ្វាយដល់អតីតកាលដើម្បីស្វែងរកអនាគតល្អ... ។

ពួកអត្ថភាពនិយមមានគោលគំនិតបោះបង់ទេព្តានិយម ពីព្រោះគេយល់ថា : ដរាបណានៅមានព្រះម្ចាស់សួគ៌ដរាបនោះនៅមានទំនាយមានព្រេងវាសនា... ។ ពួកនេះគេយល់ថា : គំនិតនេះហើយ គឺរួមសម្ព័ន្ធនិយម, គឺប្រជាធិបតេយ្យមនុស្សនិយម, គឺសម្ភារៈនិយម មិនទៅជឿផ្ដេសផ្ដាសតាមគំនិតយល់សប្តិ.. ។

ទស្សនវិទូល្បីឈ្មោះ សេក-នី-សុបស្ដី នៅសូវៀតបាន ធ្វើអត្ថាធិប្បាយថា: “លទ្ធិអត្ថភាពមនុស្សនិយម” គឺជាលទ្ធិសម្ភារៈនិយម ១ បែបដែរ ប៉ុន្តែជំហានដំបូងនៅមានចរិតបរមត្ថសាស្ត្រ (Métaphysique) ពីព្រោះពួកនេះគ្មានសមត្ថភាពក្ដាប់រាំងសតិបញ្ញាទៅទិសចលនារបស់សង្គម ... ។

ពួកអ្នកដើរតាមចលនាអវមាននិយមនេះ បានរីកចំរើននៅក្នុង Saint Germains des Prés ជាខ្លាំង ភាគច្រើនគឺពួកយុវជនស្រីប្រុសដែលធុញទ្រាន់នឹងជីវិត, ភិតភ័យនឹងសង្គ្រាម ... គេបបួលគ្នាស៊ីផឹក, លេងសើច, លាត់សើយ ... ឲ្យអស់ចិត្តនៅក្នុងជីវិតអវមាន ។

គេស្លៀកពាក់ហ៊ុហា, បង់ស្រីផឹកស្រា, រាំរោប, ប្រអប់យប់ពាសវាលព្រឹមធ្យាបាយក្រខ្វក់គ្រប់យ៉ាង ដើម្បីរកប្រាក់ប្រដាំងនឹងសិល្បបរិយា ... ។ល។ ឥទ្ធិពលរបស់គេកាន់តែកើនចំរើនឡើងយ៉ាងខ្លាំងរហូតទៅដល់ទីក្រុង ញូវ-យ៉ក, ឡុងដុង

ទឹងវែបលហៀក . . . ។ កំណាព្យរបស់លោក ប្រេវែរ (Prévert) ត្រូវបានគេសរសើរ សំឡេងច្រៀងនាង Julliette greco ត្រូវបានគេលើកតម្កើង . . . ។ ប៉ុន្តែពលនាអក្សរសាស្ត្រផន់ សម្ភារៈនិយមបែបលទ្ធិឥត្ថិភាពនិយមនេះ ពុំមានបរិតតុករល្មួយ លើកតម្កើងសាច់ឈាមពេក ប្រាសចាកសង្គមមនុស្ស, ពលកម្ម អនុវត្តិ នៅទីបំផុត ក៏ត្រូវទទួលសារភាពពលនាអក្សរសាស្ត្រ សម្ភារនិយមបដិច្ចសមុប្បាទទៅ (Matérialisme dialectique) ។

# បលនាអក្សរសាស្ត្រលោកិយសច្ចៈ Réalisme

អត្ថន័យ = អក្សរសាស្ត្រលោកិយសច្ចៈ គឺជាបលនាមួយមានទិដ្ឋាការសច្ចៈ គឺជាស្តែងការពិតឲ្យដូចពិតមែនៗ គេប្រើនយកចិត្តទុកដាក់ដល់ភាគអន់ថយ ដែលជាគុណវិបត្តិរបស់មនុស្ស ។

បលនាលោកិយសច្ចៈ ក៏មានបរិតប្រហែលគ្នានឹងពួកធម្មជាតិនិយមដែរ (Naturalisme) ប៉ុន្តែពួកធម្មជាតិនិយមគេមានប្រការពិសេសត្រង់ថា : គេស្តែងការពិតឲ្យដូចពិតមែន ប៉ុន្តែមានថែមភាគវែកញែកវះកាត់ធ្វើការបែងចែកប្រៀបធៀប...។

ពួកលោកិយសច្ចៈនេះគេយល់ថា :

– បើតាមគំនិតបុគ្គលនិយម គឺអត្តទត្តភាព.

– បើតាមគំនិតប្រលោមលោក គឺពុករលួយ

– បើតាមគំនិតបុរាណ (classique) គឺហ៊ុហាខាងក្រៅ តែអត្តរសលួយ ... ។ ហេតុនេះពួកលោកិយសច្ចៈគេមានទស្សនថា : បើឃើញស្តែងការពិតគឺពិតដល់កម្រិតណា ចំពោះ

ពពួកមនុស្សជនណា និយាយដើម្បីអ្វី អ្វីខ្លះដែលត្រូវនិយាយត្រង់ៗ ឲ្យពិត អ្វីខ្លះដែលត្រូវបន្ធូរបន្ថយ . . . ។ល។

ចលនាលោកិយសច្ចៈ មានច្រើនប្រភេទអនុលោមទៅតាមបញ្ហានិងករណីនិមួយៗ ដែលស្ដែងឡើងដូចជា :

១– សច្ចឯកជននិយម = និយាយអំពីតែការពិតរបស់បុគ្គលម្នាក់ៗ លើកតម្កើងឯកជន (បុគ្គលនិយម) ឲ្យផុតពីសង្គមរបស់មនុស្ស . . . ។

២– សច្ចលោកិយ = និយាយដល់ការពិតរបស់លោក របស់សង្គមមនុស្ស មិនយកចិត្តទុកដាក់ដល់បុគ្គលម្នាក់ៗ ឬ ចាប់មនុស្សម្នាក់ៗ ឲ្យតាមវិធានរបស់លោក . . . ។

៣– សច្ចៈស្ថាបត្យ = មើលវត្ថុទាំងអស់ឃើញនៅស្ងៀមមួយកន្លែងមិនប្រែប្រួល គ្មានស្មារតីតស៊ូដើម្បីជាមាន, គេទុកដូចជាជាន់ថ្នាក់ឬអ្នកនិពន្ធណាដែលមាននិន្នាការបែបនេះ ។

៤- <u>សប្ដុះពាក់កណ្ដាល</u> = និយាយពីការពិត ប៉ុន្តែគាត់បញ្ហាមិនបានអស់ មិនយល់វិធានប្រែប្រួលនៃធម្មជាតិ មិនយល់មានសមាសភាពច្រើន ដែលអាចផ្ដុំឲ្យបានជាសភាវៈអ្វីមួយដែលមាននៅក្នុងលោក, ក្នុងសង្គម, ក្នុងបក្រវាឡ . . . ។

៥- <u>សប្ដុះចិត្តសាស្ត្រ</u> = សំអាងតែផ្នែកខាងចិត្ត ខាងអារម្មណ៍របស់មនុស្ស យកចិត្តជាធំបំផុត ចាត់ទុកថាសម្ភារៈខាងក្រៅដែលជាហេតុបញ្ចូលចិត្ត ចាត់ទុកថាពលកម្ម ចាត់ទុកថាផលិតផលនៃសម្ភារ . . . ។

៦- <u>សប្ដុះដីវការ</u> = សំអាងតែពីរឿងរស់នៅពេលថ្ងៃការដែលមាននៅក្នុងបច្ចុប្បន្ន . . . មិនទទួលដឹងពីហេតុផលដែលមានពីមុនមក និងទៅអនាគត . . . ។

៧- <u>សប្ដុះបាយទុន</u> = យកចិត្តទុកដាក់សំអាងដល់ការរស់នៅរបស់នាយទុន អ្នកមានវណ្ណៈខ្ពង់ខ្ពស់ . . នៅក្នុងសង្គមជាន់ដើម ។ ឃើញការជឿនលឿន, ឬឃើញការល្អគួរលាស់

របស់មហាជនកើតមានការព្រួយបារម្ភ មានការក្តៅក្រហាយ សង្សឹក . . . ។

៨– សព្ទៈអ្នកមាន = យកចិត្តសំភីដោះស្រាយ ជីវភាពរញ្ជោះរញ្ជើរបស់ពួកអ្នកមាន កុដុម្ពិក អន្តុយប្រើបាក់ព្រោះ តាយផុតុកដេរម្រាយខ្ញុំកំដេរ . . . ។

៩– សព្ទៈប្រជាការ = សំភីនិយាយអំពីជីវភាពក្រខ្សត់ របស់វណ្ណៈសូទ្រៈ (កម្មករ + កសិករ) ប្រជាជនពលករ . . ដែលកំពុងតស៊ូនៅក្នុងជីវិតដើម្បីរកសេចក្តីសុខរបស់ខ្លួន . . . ។

១០– សព្ទៈធាំជ្រុង = ខំប្រឹងសំដែងឡើង ដោយ ទស្សនទូទៅយ៉ាងទូលំទូលាយរបស់ខ្លួន ចំពោះការវិវត្តន៍ជឿនលឿនទាំងស្រុងរបស់សង្គមកំដូចជារបស់មនុស្សជាតិទូទៅ . . . ។

# ចលនាអក្សរសាស្ត្រសង្គមនិយម

យកលទ្ធិសម្ភារនិយមបដិច្ចសមុប្បាទ ឬលទ្ធិសម្ភារនិយមប្រវត្តិសាស្ត្រជាមូលដ្ឋានក្នុងការទិទៀនរិះគន់ ឬក្នុងការនិពន្ធរឿងរ៉ាវគ្រប់ទាំងអស់ ។

អត្ថរសគឺយកស្មារតីតស៊ូវណ្ណៈធ្វើជាមូលដ្ឋានឲ្យការចលនារបស់តួអង្គនាដសកម្ម ។

គោលបំណងគឺណែនាំមនុស្សឲ្យទៅកាន់លទ្ធិសង្គមនិយមនិងរួមសម្ព័ន្ធនិយមអន្តរជាតិ ក្រោមការដឹកនាំរបស់គណៈបក្សពលករនិងកម្មករ . . . ។

មធ្យោបាយសំខាន់ គឺដាក់នយោបាយឃោសនាឡើងជួរមុខ ក្នុងការចលនាមនុស្សបំរើផលប្រយោជន៍របស់សង្គម ។ ផ្នែកសិល្បៈក៏ដូចជាផ្នែកគំនូរចម្លាក់ផ្សេងៗ ត្រូវបំរើគោលបំណងនយោបាយជាដាច់ខាត ។

ផ្នែកសង្គមនិយមគេយល់ថា: អក្សរសាស្ត្រគឺជាមធ្យោបាយ

សម្រាប់ឃោសនា, សម្រាប់បំរើសង្គម . . . មិនត្រូវឲ្យក់ឃរមាន នៅដាច់ដោយឡែកពីសង្គមមនុស្សបានទេ ធ្វើបានបែបនេះ ទើបហៅថាអក្សរសាស្ត្រមានប្រយោជន៍ . . . ។ល។

# អក្សរសាស្ត្រនិមិត្តរូបារម្មណ៍ Symbolisme.

<u>អត្ថន័យ</u> = ចលនាអក្សរសាស្ត្រនិមិត្តរូបារម្មណ៍មាននិតិការស៊ីជម្រៅទៅក្នុងចិត្តថ្មើមឬមនោសញ្ចេតនាមនុស្សយ៉ាងលាក់លៀមស្ងាត់កំបាំងដោយនិមិត្តរូបផ្សេងៗ មកប្រៀបធៀបជាឧបមា... ។

<u>មនោគមវិជ្ជា</u> = មានការលំបាកប្រើនក្នុងការសំដែងលាតត្រដាង, ត្រូវប្រមូលឲ្យអស់នូវសមត្ថភាពសិល្បៈដើម្បីការសំដែងដ៏ជ័យជំនះ ។

ពេលអស់នូវបណ្តាបែបបទពីដើម ប្រើវិធីថ្មី អត្ថន័យថ្មី. បែបបទ (Style) ថ្មី ដើម្បីលាតត្រដាងឲ្យបាននូវការបង្ហាញផ្លារបស់សតិអារម្មណ៍ ។

ដូរ្យតន្ត្រីមាននាទីយ៉ាងសំខាន់នៅក្នុងចលនានេះ នៅក្នុងការនិពន្ធតែងៗ P. Verlaine និយាយថា: "ដូរ្យតន្ត្រីសិន, ហើយដូរ្យតន្ត្រី បន្ទាប់មកទេះតែដូរ្យតន្ត្រីទៀត" ។ និយាយបៀបនេះ

ពិបាកយល់ណាស់ ប៉ុន្តែយើងត្រូវមានទស្សនថា : ជួរជ្រើពនាំឲ្យមនុស្សចាប់អារម្មណ៍រហ័សណាស់ មានបរិតផ្ទាល់ផង . . . ៗ និយាយមួយបែបទៀតថា : អត្ថបទក្នុងចលនានិមិត្តរូបារម្មណ៍មានការពិបាកយល់ច្រើនចំពោះអ្នកអាន ប៉ុន្តែបើយើងអានមានបែបបទ (ធ្វើបទ) ឡើងចុះ, ធ្វើឲ្យមានពណ៌សម្បុរខុសៗគ្នា, យើងអាចយល់បានមួយភាគយ៉ាងឆាប់ដែរ ហើយបន្ទាប់មកយើងត្រូវប្រឹងធ្វើការសិក្សាដើម្បីយល់ថែម . . . ៗ

ដើម្បីឲ្យអ្នកអានកំណាព្យ ឬ អត្ថបទយល់បានម្តងបន្តិចៗ (កុំឲ្យយល់តាំងស្រុងតែមួយភ្លែត) តាមអក្សរទឹងតាមឃ្លាទីមួយៗ អ្នកនិពន្ធ មុននឹងនិពន្ធរឿងអ្វីមួយ ត្រូវបំបាត់ចោលបីភាគបួននៃលក្ខណៈសភាវៈនោះដើម្បីនាំឲ្យអ្នកអានមានការពិចារណារករកដោយខ្លួនឯង ៗ ជាពាក្យលោក S. Mallarmé ៗ

ចលនានិមិត្តរូបារម្មណ៍ ក្នុងពេលក្រោយមកបានក្លាយទៅជាស្មុគ្រស្មាញគ្មានរកផ្លូវឃើញ (Hermétique) ហើយត្រឡប់

ទៅជាមិនពិតតទៀងទាត់ទៅវិញ (Surnaturalisme) ។

និយាយសង្ខេបទៅចលនានិមិត្តរូបារម្មណ៍មានបរតសិល្បៈ ដើម្បីសិល្បៈ មិនមែនសិល្បៈដើម្បីបំរើជីវភាពមនុស្ស បំរើសង្គមមនុស្សទេ . . . ។

# ពិសេសចំពោះអក្សរសាស្ត្រខ្មែរ

ក្នុងការនិយាយពន្យល់អក្សរសាស្ត្រខ្មែរមួយផ្នែកខាងចលនា ព្រហ្មនិយមភាគខ្លះ យើងច្រើនងឿងឆ្ងល់និងយល់មិនច្បាស់នូវ ពាក្យមួយម៉ាត់ ដែលគេហៅថា "អវតារ" ។ ឧទាហរណ៍ ដូចជា ព្រះរាមជាតួអង្គនារាយណ៍អវតារ ... ។ល។ ចុះអវតារ នេះ វាមានឫសគល់យ៉ាងណាទៅ ?

នៅក្នុងបណ្ដាវណ្ណកម្ម ដែលជាចលនាអក្សរសាស្ត្រផ្នែក ព្រហ្មនិយមព្រះវិស្ណុ (ព្រះនារាយណ៍) ជាអ្នកមាននាទីបង្កើត លោក មាននាទីរក្សាលោកនិងការពារសភាវៈល្អនិយាយរួមបើ យើងរាប់រៀបតាំងពីខឿនវប្បធម៌របស់ជនអារ្យនៅប្រទេសឥណ្ឌៀ វិញ ... ។ ព្រះវិស្ណុនេះហើយដែលគេទុកជាអ្នកការពារ សាសនាព្រហ្ម ផ្ចាញ់ផ្ចាលសត្រូវមកបៀតបៀនហើយជាបុត្រ របស់ព្រះបរព្រហ្ម ។

បើព្រះវិស្ណុជាអ្នកបង្កើតលោក ក្នុងលោកតាំងមូលវាតែង តែមានសភាវៈល្អនិងអាក្រក់ជរមានជាមួយគ្នា ហេតុដូច្នេះ បាន

សេចក្ដីថាព្រះវិស្ណុបង្កើតសភាវៈល្អនិងអាក្រក់ព្រមជាមួយគ្នា ។ ក្នុងនាទីការពារសភាវៈល្អ បើសិនណាជាព្រះវិស្ណុបណ្ដោយទុកឲ្យសភាវៈអាក្រក់បុករុកធ្វើបាបសភាវៈល្អទៅ បានសេចក្ដីថាព្រះវិស្ណុនេះមានអយុត្តិធម៌នៅក្នុងខ្លួន ហើយម្យ៉ាងទៀតក្នុងលោកនេះក៏នឹងក្លាយទៅជាលោកពោរពេញទៅ ដោយសេចក្ដីអយុត្តិធម៌ថែមទៀតផង ហេតុនេះព្រះវិស្ណុត្រូវមានភារៈការពារសភាវៈល្អ ផ្ចាញ់ផ្ចាលសភាវៈអាក្រក់ទៅវិញ ។

ក្នុងនាទីបង្កើតលោកទាំងមូលគឺព្រះវិស្ណុ ក្នុងនាទីផ្ចាញ់ផ្ចាលសភាវៈអាក្រក់ដើម្បីការពារសភាវៈល្អ គឺព្រះវិស្ណុទៀត... ដូច្នេះយើងឃើញថាក៏មានការផ្ទុយនៅក្នុងគំនិតព្រះវិស្ណុ ហើយម្យ៉ាងទៀត ក៏ដូចជាមិនសូវសមរម្យផង ក្នុងការៈរបស់ខ្លួនម្ដងបង្កើតម្ដងបំផ្លាញ... ។

ដើម្បីកែច្នៃឲ្យភារៈរបស់ព្រះវិស្ណុ ( យួនចិនច្រើនហៅថាព្រះក្វាន.អ៊ុម គឺព្រះម៉ែ ) មានបរិតតក្កសាស្ត្រសមរម្យល្អក្នុង

ការបំផ្លាញសភាវៈអាក្រក់ដែលខ្លួនបង្កើតនោះ ព្រះវិស្ណុត្រូវកាឡាខ្លួនជាសភាវៈផ្សេងៗ មកផ្លាញ់ផ្លាល វិធីកាឡាខ្លួននេះហើយដែលគេហៅថា "អវតារ" ដូចជាពាក្យថា នារាយណ៍អវតារ, .. ។ល។

ពាក្យថានារាយណ៍អវតារ គឺជាព្រះនារាយណ៍កាឡាខ្លួនមកជាសភាវៈផ្សេងឲ្យខុសពីរូបអង្គព្រះនារាយណ៍ (វិស្ណុ) ដើម្បីប្រតិបត្តិការៈអ្វីមួយដូចជាផ្លាញ់ផ្លាលសភាវៈអាក្រក់ជាដើម...។

បើតាមរឿងពីដើម ព្រះនារាយណ៍កាឡាខ្លួនច្រើនលើកច្រើនគ្រាណាស់ ដើម្បីទប់ទល់សត្រូវការពារសភាវៈល្អមានហេតុទៅដល់រាប់ពាន់ដងផង ប៉ុន្តែជាធម្មតាគេច្រើននិយាយតែ ១០ គ្រាទេ ដូចជា: "នារាយណ៍ទសាវតារ"

---

## នារាយណ៍ទសាវតារ (ព្រះនារាយណ៍កាឡាខ្លួន ១០ គ្រា)

ក្នុងគម្ពីរនារាយណ៍ទសាវតារ គេនិយាយថាព្រះនារាយណ៍កាឡាខ្លួន ១០ ដង ក្នុងគប្បីការពារគម្ពីរវេទ ការពារសាសនា

ព្រហ្មទីនសការៈល្អដោយមានរឿងមួយ ៗ យកមកបញ្ជាក់ដូចគ្នា នឹងរឿងជាតកផ្នែកត្រូទិយមអីចឹងដែរ ៖

១- មត្ស្យាវតារ   ក្លាយជាត្រី (សម្លាប់យក្សហៃគ្រីព ការពារវេទ)

២- កូរមាវតារ   –,,– អណ្តើក (កូរទឹកអម្រិត)

៣- វរាហាវតារ   –,,– ជ្រូកព្រៃ (សម្លាប់យក្ស យកមន្តវេទមកវិញ)

៤- នរសិង្ហាវតារ –,,– មនុស្សពាក់កណ្តាលសិង្ហ ពាក់កណ្តាល (សម្លាប់យក្សពិកាធ)

៥- វាមណាវតារ   –,,– ព្រាហ្មណ៍តឿ (ត្រីវិក្រម ផ្ចាញ់ក្រុងពាលី)

៦- បរសុរាមាវតារ –,,– ព្រាហ្មណ៍កាន់ពូថៅ

៧- រាមចន្ទ្រាវតារ –,,– ព្រះរាមចន្ទ្រ (ក្សត្រ-សុរិយវង្សក្នុងរឿងរាមកេរ្តិ៍)

៨- ក្រឹស្ណាវតារ កាឡាជាស្តេចក្រឹស្ណា (ក្សត្រព្រឹ
វង្សក្នុងរឿងមហាភារតយុទ្ធ)

៩- ពុទ្ធាវតារ -,, ព្រះពុទ្ធសមណគោតម

១០- ក័លក្យាវតារ -,,- ព្រះក័លកិ (ដែលនឹង
មានក្នុងអនាគតនៅចុងកលិយុគនេះ) ។

## ទសជាតក៍ (១០ រឿង)

១- តេមិយជាតក កសាងបំពេញនេក្ខម្មបារមី (គឺ
ការចាកចេញឲ្យផុតស្រឡះពីកាមសៅហ្មង)

២- ជនកជាតក កសាងបំពេញវិរិយបារមី (គឺការ
កាន់ខ្ជាប់នូវសេចក្តីព្យាយាម)

៣- សុវណ្ណសាមជាតក កសាងបំពេញមេត្តា
បារមី (គឺការរាប់អានសព្វសត្វគ្មានរើសអើង)

៤- នេមិរាជជាតក កសាងបំពេញអធិដ្ឋានបារមី
(គឺការខំខ្ជួសរកឲ្យឃើញការពិត)

៥- មហោសថជាតក កសាងបំពេញបញ្ញាបារមី (គឺការធ្វើឲ្យបេះដូងមានបញ្ញា នឹងរកសេចក្ដីពិតក្នុងលោក...) ។

៦- ភូរិទត្តជាតក កសាងបំពេញសីលបារមី (គឺការរក្សាឬតមខ្លួនឲ្យបាននឹងនួនបរិសុទ្ធល្អផង់កាយវាចាចិត្ត...) ។

៧- ចន្ទកុមារជាតក កសាងខន្តីបារមី (គឺការរក្សាសេចក្ដីអត់ធន់អំណត់ឲ្យខ្ជាំងមាំមួន) ។

៨- នារទជាតក កសាងបំពេញឧបេក្ខាបារមី (គឺតាំងចិត្តជាកណ្ដាលព្រងើយកន្តើយ ចំពោះសការៈទាំងអស់) ។

៩- វិធុរជាតក កសាងបំពេញសច្ចៈបារមី (គឺការកាន់ឲ្យខ្ជាប់ខ្ជួនទូវពាក្យសំដីពិតប្រាកដ) ។

១០- វេស្សន្តរជាតក កសាងបំពេញទានបារមី (គឺ

ការលះបង់ទ្រព្យសម្បត្តិ ដាក់ទានដល់អ្នកទាំងពួង គ្មានរើសមុខ ) ។

ដើម្បីបានត្រាស់ជាព្រះសម្មាសម្ពោធិញ្ញាណ គ្រប់ពុទ្ធបេក្ខទាំងឡាយ (ពុទ្ធង្កុរ) ត្រូវតែកសាងឲ្យបានបារមីទាំងនេះ ហេតុនេះហើយ បានជាយើងឃើញនៅក្នុងចលនាអក្សរសាស្ត្រពុទ្ធនិយមខ្មែរយើង មានជាតកជាច្រើនអនេកដែលនិទានអំពីដំណើរព្រះពោធិសត្វទ្រង់យោនយកកំណើតជាសភាវៈផ្សេងៗ ដើម្បីកសាងសន្សំឲ្យបានបារមីទាំង ១០ នេះ ពីព្រោះបារមីនីមួយៗមានចែកចេញជា ៣ ថ្នាក់ទៅទៀត គឺជាថ្នាក់ធម្មតាមួយ ថ្នាក់កណ្ដាលមួយ និងថ្នាក់ខ្ពស់មួយទៀត . . . ។ល។

---

សូមរង់ចាំអាន និងមានផ្សាយនៅពេលជិតនេះ

ពិសោធន៍ និងការល្បង និពន្ធ៍ប្រធាន ;

ចរិយា, ការសិតនិងខ្លួនទៅ

ដោយ ហ៊ុន - គឹមសៀ

7488/5
1

តម្លៃ ២០រុ ០០